សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**

# ដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ម៉ិល ចន្ថា**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ព្រុំ ទេវី**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច**
ឯកទេស **គ្រប់គ្រង** ជំនាន់១៦ ជំហាន២

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេររបាយការណ៍ ២០២១

# អារម្ភកថា

ព្រៃឈើមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅ និងភាពសុខុមាលភាពរបស់ប្រជាជន និងសត្វគ្រប់មជ្ឈដ្ឋាននៅលើសកលលោកយើងនេះ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ព្រៃឈើនៃប្រទេសកម្ពុជា ត្រូវបានមើលឃើញថាមានការថយចុះគួរឱ្យកត់សម្គាល់ទៅលើគម្របព្រៃឈើសរុប និងគម្របព្រៃស្អុក ដោយសារកំណើននៃចម្ការដំណាំ ជាពិសេសកៅស៊ូ ការបង្កើតព្រៃការពារ និងសហគមន៍ព្រៃឈើ និងបញ្ហាដែលកំពុងបន្តជាមួយនឹងការកាប់ឈើខុសច្បាប់។ ដើម្បីបង្កើនការការពារ ការគ្រប់គ្រងធនធានព្រៃឈើ ដែលមានស្រាប់ឱ្យមាននិរន្តរភាព និងការដាំដើមឈើឡើងវិញលើដីព្រៃធរិល ព្រមទាំងជំរុញឱ្យមានការចូលរួមគ្រប់គ្រងធនធានព្រៃឈើនោះ ទើបមានរបាយការណ៍ស្រាវជ្រាវ បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើប្រធានបទ «**ដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ ដំណាក់អ្នកតាថ្មពូន**» ស្ថិតនៅឃុំស្រែក្នុង ស្រុកជុំគីរី ខេត្តកំពត។

របាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះបានលើកឡើងអំពី ទស្សនៈវិជ្ជាពាក់ព័ន្ធនឹងការគ្រប់គ្រង មុខងារនៃការគ្រប់គ្រង តួនាទីនិងជំនាញនៃការគ្រប់គ្រង រចនាសម្ព័ន្ធអង្គភាពចាត់តាំង សិទ្ធិអំណាចក្នុងការគ្រប់គ្រង ការធ្វើប្រតិភូកម្មនៃការគ្រប់គ្រងសកម្មភាពការងារ រចនាសម្ព័ន្ធរបស់សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើនិងអនុគណៈកម្មការគ្រង់គ្រងសហគមន៍ព្រៃឈើ សមាសភាពក្រុមសម្របសម្រួលនិងអ្នកទ្រទ្រង់សហគមន៍ព្រៃឈើ ការចូលជាសមាជិកសហគមន៍ព្រៃឈើ នាទីភារកិច្ចសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកសហគមន៍ព្រៃឈើស្ថាប័ននិងអាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវ នីតិវិធី និងដំណើរការរៀបចំសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ផែនការគ្រប់គ្រងព្រៃសហគមន៍ ប្រភពហិរញ្ញវត្ថុទ្រទ្រង់សហគមន៍ព្រៃឈើ ការប្រើប្រាស់ធនធានព្រៃសហគមន៍របស់សហគមន៍ព្រៃឈើ ការរៀបចំឱ្យមានបញ្ជីសារពើភ័ណ្ឌព្រៃឈើសហគមន៍ដំណាក់អ្នកតាថ្មពូន។ល។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មួយនេះនឹងបានរួមចំណែកក្នុងការផ្សព្វផ្សាយ និងផ្តល់ព័ត៌មានដល់មិត្តអ្នកអាន ជានិស្សិតជំនាន់ក្រោយបានជាឯកសារជំនួយស្មារតីក្នុងការសិក្សាស្រាវជ្រាវ។ ក្នុងការសរសេរ និងចងក្រងសៀវភៅនេះ ខ្ញុំបាទបានស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ខ្ពស់។ ទន្ទឹមនឹងនេះ ខ្ញុំបាទក៏សូមស្វាគមន៍ជានិច្ចនូវគំនិតរិះគន់កែលម្អលើចំណុចខ្វះខាតទាំងឡាយដែលមាននៅក្នុងរបាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ ពីសំណាក់មិត្តអ្នកអាន និងអ្នកស្រាវជ្រាវទាំងអស់ដោយក្តីសោមនស្សរីករាយក្រៃលែង។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ម៉ិល ចន្ទា** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រង ជំនាន់ទី១៦ ជំហាន២ ឆ្នាំសិក្សា២០២០-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ដែលបានចងក្រងជារបាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើប្រធានបទ «**ដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួន**»

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងស្មោះអស់ពីដួងចិត្តចំពោះ៖**

- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោកនាយក នាយករងថ្នាក់ក្រោយបរិញ្ញាបត្រ ប្រធានការិយាល័យសិក្សា និងមន្ត្រីបុគ្គលិកសិក្សាទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំយកចិត្តទុកដាក់បំពេញភារកិច្ចតាមតម្រូវការរបស់និស្សិត ប្រកបដោយប្រសិទ្ធភាពខ្ពស់។
- សាស្ត្រាចារ្យបណ្ឌិត **ព្រំ ទេវី** ដែលបានខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់ ធ្វើការលើកទឹកចិត្ត ព្រមទាំងចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីណែនាំខ្ញុំបាទក្នុងដំណើរការនៃចងក្រងសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ តាំងពីការចាប់ផ្តើមរហូតមកដល់ទទួលជោគជ័យ និងបានសម្រេចជាស្ថាពរ។
- **អ្នកមានគុណទាំងទ្វេរ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សាតាំងពីតូចរហូតដល់ធំ ព្រមទាំងផ្តល់ការអប់រំដល់រូបខ្ញុំបាទ ឱ្យទទួលបាននូវចំណេះដឹងខ្ពង់ខ្ពស់ ដើម្បីក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម ដោយពុំគិតពីការលំបាកនឿយហត់របស់លោកទាំងទ្វេឡើយ។ ជាពិសេសលោកទាំងទ្វេបានផ្តល់ការប្រៀនប្រដៅ ព្រមទាំងបានអប់រំខ្ញុំបាទដោយក្តីស្រឡាញ់ មេត្តា ករុណា ទាំងកំលាំងកាយ និងកំលាំងចិត្ត ព្រមទាំងផ្គត់ផ្គង់ការសិក្សាថែមទៀត។
- សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយបង្ហាត់បង្រៀនតាំងពីថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ប្រកបដោយគុណភាព។

ជាចុងបញ្ចប់ ខ្ញុំបាទសូមបួងសួង និងរំលឹកដល់វត្ថុស័ក្តិសិទ្ធិទាំងពួងក្នុងលោក និងគុណព្រះរតនៈត្រ័យទាំងបី សូមជួយប្រោសព្រំ ដល់សាស្ត្រាចារ្យ និងអ្នកមានគុណទាំងទ្វេរ ឱ្យជួបតែសុភមង្គល និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

បញ្ជីតារាង ..... i
បញ្ជីរូបភាព ..... ii

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១
២. ចំណូលបញ្ហានៃការស្រាវជ្រាវ ..... ១
៣. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ២
៤. វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ២
៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ..... ៣
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៤
៧. ប្រតិទិននៃដំណាក់កាលស្រាវជ្រាវ ..... ៤

## ជំពូកទី១
## រំលឹកទ្រឹស្តី

១.១. អ្វីទៅជាការគ្រប់គ្រង? ..... ៥
១.១.១. និយមន័យនៃការគ្រប់គ្រង ..... ៥
១.១.២. កម្រិតនៃការគ្រប់គ្រង ..... ៦
១.១.៣. មុខងារនៃការគ្រប់គ្រង ..... ៧
១.១.៣.១. ការធ្វើផែនការ (Planning) ..... ៨
១.១.៣.២. ការចាត់តាំង (Organzing) ..... ៨
១.១.៣.៣. បុគ្គលិក (Staffing) ..... ៨
១.១.៣.៤. ការដឹកនាំ (Directing) ..... ៨
១.១.៣.៥. ការត្រួតពិនិត្យ (Controlling) ..... ៨
១.២. ទស្សនៈអំពីចរិយាធម៌នៃការគ្រប់គ្រង ..... ៩
១.២.១. សម្មិតកម្មនៃទ្រឹស្តី X "អ៊ិច" ..... ៩
១.២.១. សម្មិតកម្មនៃទ្រឹស្តី Y "វ៉ាយ" ..... ៩
១.៣. សិទ្ធិអំណាចក្នុងការគ្រប់គ្រង ..... ១០

១.៤. ការធ្វើប្រតិភូកម្មនៃការគ្រប់គ្រងសកម្មភាពការងារ ................................................................. ១០
១.៤.១. អ្វីជាការធ្វើប្រតិភូកម្ម? ................................................................. ១០
១.៤.២. ការធ្វើប្រតិភូកម្មការងារ ................................................................. ១០
១.៥. សហគមន៍ព្រៃឈើ ................................................................. ១១
១.៥.១. ទស្សនៈនៃសហគមន៍ព្រៃឈើ ................................................................. ១២
១.៥.២. ផែនការគ្រប់គ្រងព្រៃសហគមន៍ ................................................................. ១២
១.៦. គោលនយោបាយរាជរដ្ឋាភិបាលក្នុងការគាំទ្រសហគមន៍ព្រៃឈើ ................................................................. ១៣

## ជំពូកទី២

## ស្ថានភាពទូទៅសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

២.១. ភូមិសាស្ត្រសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ................................................................. ១៥
២.១.១. ទីតាំងភូមិសាស្ត្រ ................................................................. ១៥
២.១.២. ស្ថានភាពដី ................................................................. ១៦
២.១.៣. ផែនដីព្រៃសហគមន៍ ................................................................. ១៦
២.២. ទស្សនៈវិស័យ និងបេសកកម្ម ................................................................. ១៧
២.២.១. ទស្សនៈវិស័យ ................................................................. ១៧
២.២.២. បេសកកម្ម ................................................................. ១៧
២.៣. ការជ្រើសរើសសមាសភាពគណៈកម្មការគ្រប់គ្រង ................................................................. ១៧
២.៤. អាណត្តិរបស់គណៈកម្មការគ្រប់គ្រង ................................................................. ១៨
២.៥. រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រង ................................................................. ១៩
២.៦. សមាសភាពគណៈកម្មការគ្រប់គ្រង ................................................................. ១៩
២.៧. ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មការ និងអនុគណៈកម្មការគ្រប់គ្រង ................................................................. ២១
២.៧.១. ភារកិច្ច ................................................................. ២១
២.៧.២. ការទទួលខុសត្រូវ ................................................................. ២១
២.៧.២.១. ការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រង ................................................................. ២១
២.៧.២.២. ការទទួលខុសត្រូវរបស់អនុគណៈកម្មការគ្រប់គ្រង ................................................................. ២២

## ជំពូកទី៣

## ដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួន


៣.១. ដំណើរការនៃការរៀបចំបង្កើតសហគមន៍ព្រៃឈើ ........ ២៤

៣.២. ការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍........ ២៥

៣.៣. កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ........ ២៥

៣.៣.១. កិច្ចប្រជុំសាមញ្ញ........ ២៥

៣.៣.២. កិច្ចប្រជុំវិសាមញ្ញ........ ២៧

៣.៣.៣. របៀបរបបប្រជុំ........ ២៨

៣.៣.៤. កំណត់ហេតុនៃអង្គប្រជុំ ........ ២៨

៣.៤. ការប្រើប្រាស់ធនធានព្រៃឈើសហគមន៍........ ២៩

៣.៤.១. ការប្រើប្រាស់ធនធានព្រៃឈើសហគមន៍ដោយសមាជិកសហគមន៍ព្រៃឈើ ........ ២៩

៣.៤.២. ការប្រើប្រាស់ធនធានព្រៃឈើសហគមន៍ក្រៅពីសមាជិកសហគមន៍ព្រៃឈើ ........ ២៩

៣.៤.៣. ការបែងចែកផលប្រយោជន៍ក្នុងសហគមន៍ ........ ២៩

៣.៤.៤. ការបណ្តុះបណ្តាលសមាជិកសហគមន៍........ ៣០

៣.៤.៥. ការលើកទឹកចិត្តដល់សមាជិកសហគមន៍ព្រៃឈើ ........ ៣០

៣.៥. វិធានការការពារសហគមន៍ព្រៃឈើ ........ ៣១

៣.៥.១. ការហាមឃាត់ក្នុងសហគមន៍ព្រៃឈើ ........ ៣១

៣.៥.១.១. ការប្រមូលផល-អនុផលព្រៃឈើ........ ៣១

៣.៥.១.២. ការបង្កើតរោងសន្និធិ សិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ........ ៣១

៣.៥.១.៣. ការឈូសឆាយស្ថាបនាផ្លូវសាធារណៈ ........ ៣២

៣.៥.១.៤. សកម្មភាពផ្សេងៗ ........ ៣២

៣.៥.២. ការដោះស្រាយទំនាស់ក្នុងសហគមន៍ព្រៃឈើ........ ៣៣

៣.៥.៣. ការដាក់ទណ្ឌកម្មចំពោះជនដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ ........ ៣៤

៣.៦. ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយនៃការគ្រប់គ្រង ........ ៣៥

៣.៦.១. ចំណុចខ្លាំង ........ ៣៥

៣.៦.២. ចំណុចខ្សោយ........ ៣៥

**សេចក្តីសន្និដ្ឋាន**................................................................................................................... ៣៨
**អនុសាសន៍**............................................................................................................................ ៣៩
**ឯកសារយោង/គន្ថនិទ្ទេស**

# បញ្ជីតារាង


តារាងទី១ ៖ រចនាសម្ព័ន្ធសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ........................................................ ១៩

តារាងទី២ ៖ ផែនការប្រជុំរបស់ប្រធានក្រុម ........................................................................................ ២៦

តារាងទី៣ ៖ ផែនការប្រជុំរបស់គណៈ-អនុកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ....................................... ២៦

តារាងទី៤ ៖ ផែនការប្រជុំរបស់សមាជិកសហគមន៍ព្រៃឈើ ............................................................... ២៧

# បញ្ជីរូប

រូបភាពទី១ ៖ Level of Management ........ ៦

រូបភាពទី២ ៖ Function of Management ........ ៧

រូបភាពទី៣ ៖ ផែនទីសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ........ ១៦

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រៃឈើមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅ និងភាពសុខុមាលភាពរបស់ប្រជាជន និងសត្វគ្រប់មជ្ឈដ្ឋាននៅលើសកលលោកយើងនេះ បន្ថែមពីលើការផ្ដល់ធនធានសម្រាប់សេចក្ដីត្រូវការប្រចាំថ្ងៃព្រៃឈើបានផ្ដល់សារៈសំខាន់ផ្នែកវប្បធម៌ និងបរិស្ថានថែមទៀត ជាហេតុទើបឱ្យមានការបង្កើតនូវការគ្រប់គ្រងតំបន់ព្រៃឈើនៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ១៩៧៣ ប្រទេសកម្ពុជា មានព្រៃឈើសរុបចំនួន ១៣,១៤លានហិកតា ដែលក្នុងនោះព្រៃស្ដុកមានចំនួន ៧,៦លានហិកតា គិតត្រឹមឆ្នាំ២០១៤ គម្របព្រៃឈើសរុបបានធ្លាក់ចុះដល់ ៨,៧លានហិកតា។ ជាលើកដំបូងក្នុងរយៈពេល ៤១ឆ្នាំ ដែលភាគរយនៃគម្របដីមិនមែនព្រៃ (៤៨,៤ភាគរយ) មានទំហំធំជាងគម្របព្រៃឈើ (៤៧,៧ភាគរយ) ព្រៃស្ដុកបានថយចុះសល់តែ ៣លានហិកតា។ ដោយហេតុថា ៨០ភាគរយ នៃចំនួនប្រជាជនសរុបរបស់កម្ពុជារស់នៅតាមតំបន់ជនបទ ហេតុនេះព្រៃឈើដើរតួនាទីយ៉ាងសំខាន់ក្នុងជីវភាពរស់នៅ ព្រោះវាជាប្រភពនៃអាហារ ឱសថបុរាណ សម្ភារៈសំណង់ អុសចំអិនអាហារ ឧបករណ៍សម្រាប់ធ្វើផ្ទះ ចំណីអាហារ ការដឹកជញ្ជូន (ដូចជាឈើសម្រាប់ធ្វើរទេះ) និងឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃជាដើម ហើយក៏ជាប្រភពនៃវត្ថុធាតុដើម និងទំនិញសម្រាប់ជំនួញខ្នាតតូច។ លើសពីការចិញ្ចឹមជីវិត ព្រៃឈើក៏មានប្រយោជន៍ផ្នែកបេតិកភ័ណ្ឌ និងវប្បធម៌ជាច្រើនសម្រាប់មនុស្ស។ ជាទូទៅមានការប្រែប្រួលតាមវិសាលភាពនៃតំបន់ព្រៃឈើដែលពួកគេពឹងពាក់ភាគច្រើននៃសហគមន៍ប្រើប្រាស់ព្រៃឈើ សម្រាប់គោលបំណងទាំងពីរយ៉ាងគឺ សម្រាប់ប្រើប្រាស់ជាតម្រូវការ (មិនលក់ដូរ) និងផលិតផលសម្រាប់លក់ដូរ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកព្រៃឈើជាទ្រព្យសម្បត្តិរបស់រដ្ឋដែលមានជាអាទិ៍ដីធ្លី ភ្នំ សមុទ្រ បាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗ ដែលបានកំណត់ថាជារបស់រដ្ឋ។ លើសពីនេះទៅទៀត រដ្ឋត្រូវការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពលប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ព្រៃឈើនៃប្រទេសកម្ពុជាយើង ឃើញថាមានការថយចុះគួរឱ្យកត់សម្គាល់ទៅលើគម្របព្រៃឈើសរុប និងគម្របព្រៃស្ដុក ដោយសារកំណើននៃចម្ការដំណាំ ជាពិសេសកៅស៊ូ ការបង្កើតព្រៃការពារ និងសហគមន៍ព្រៃឈើ និងបញ្ហាដែលកំពុងបន្តជាមួយនឹងការកាប់ឈើខុសច្បាប់។ ហេតុនេះហើយ

វាជាការចំបាច់ក្នុងគ្រប់គ្រងព្រៃឈើ ដែលត្រូវមើលឱ្យឃើញនូវភាពពិសិដ្ឋរបស់ព្រៃឈើ និងត្រូវទទួលស្គាល់នៃតម្រូវការ និងតម្លៃផ្សេងៗគ្នារបស់ព្រៃឈើ ដើម្បីបង្កើនការការពារ ការគ្រប់គ្រងធនធានព្រៃឈើ ដែលមានស្រាប់ឱ្យមាននិរន្តរភាព និងការដាំដើមឈើឡើងវិញលើដីព្រៃរេចរិល។ ការកើនឡើងនៃសហគមន៍ព្រៃឈើនៅប្រទេសកម្ពុជា គឺជាឆ្លើយតបទៅនឹងភាពខ្វល់ខ្វាយពីការបាត់បង់ព្រៃឈើ នៅក្នុងប្រទេសកម្ពុជាយ៉ាងឆាប់រហ័សពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ការកើនឡើងនៃសហគមន៍ព្រៃឈើនៅប្រទេសកម្ពុជា គឺជាឆ្លើយតបទៅនឹងភាពខ្វល់ខ្វាយពីការបាត់បង់ព្រៃឈើនៅក្នុងប្រទេសកម្ពុជាយ៉ាងឆាប់រហ័សពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ កំណត់ក្របខណ្ឌសម្រាប់ការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សព្រៃឈើ នៅក្នុងប្រទេសកម្ពុជា។ ព្រៃឈើស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ ដែលជាផ្នែកមួយនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មធ្យោបាយដែលព្រៃឈើត្រូវបានគ្រប់គ្រង មានឥទ្ធិពលយ៉ាងខ្លាំងទៅលើផ្នែកជាច្រើននៃជីវិត ដែលមានចែងនៅក្នុងឃ្លាបេសកកម្មនៃកម្មវិធីព្រៃឈើជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១០-២០២៩៖

*«បេសកកម្មរួមរបស់យើង គឺដើម្បីជម្រុញការគ្រប់គ្រង និងការអភិវឌ្ឍព្រៃឈើប្រកបដោយនិរន្តរភាព សម្រាប់ការរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ធ្វើឱ្យជីវភាពប្រសើរឡើង មានកំណើនសេដ្ឋកិច្ច និងការការពារបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងបេតិកភ័ណ្ឌវប្បធម៌របស់យើង»*

## ៣. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីបង្កើនការការពារ ការគ្រប់គ្រងធនធានព្រៃឈើដែលមានស្រាប់ឱ្យមាននិរន្តរភាព និងការដាំដើមឈើឡើងវិញលើដីព្រៃរេចរិល ព្រមទាំងជំរុញឱ្យមានការចូលរួមគ្រប់គ្រងធនធានព្រៃឈើនោះ។ ដើម្បីឆ្លើយតបទៅនឹងការបរិយាយខាងលើ អ្នកស្រាវជ្រាវបង្កើតសំណួរមួយចំនួនឈានទៅការស្រាវជ្រាវអំពីសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួន៖

១. តើដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួន ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២. សហគមន៍ព្រៃឈើមានទស្សនៈក្នុងការគ្រប់គ្រងដោយរបៀបណាឱ្យមាននិរន្តរភាព និងប្រសិទ្ធភាព?

៣. តើសហគមន៍ព្រៃឈើបានទាញយកផលប្រយោជន៍ពីព្រៃសហគមន៍មកចែកដល់សមាជិក ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋានប្រើប្រាស់ប្រកបដោយតម្លាភាពយ៉ាងម្តេច?

## ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីចង់ក្រងចេញជារបាយករណ៍ស្រាវជ្រាវនេះបាន គឺប្រមូលបានពីប្រភពទិន្នន័យ ២ ប្រភេទគឺៈ

១. **ទិន្នន័យចម្បង៖** ការជួបសំភាសន៍សមាជិកសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួនចំនួន ០៨នាក់ ក្នុងនោះរួមមានប្រុសចំនួន៤នាក់ ស្រីចំនួន៤នាក់ ដែលជាប្រធានសហគមន៍១នាក់ និងសមាជិកសហគមន៍៧

នាក់ ដោយមានការអង្កេតផ្ទាល់ក្នុងសហគមន៍។ ស្រាវជ្រាវឯកសារដកស្រង់យកចំណុចសំខាន់ៗដែលទាក់ទងនឹងប្រធានបទ ដើម្បីយកមកផ្គុំគំនិតចងក្រងសរសេរជារបាយការណ៍ស្រាវជ្រាវ។

**២. ទិន្នន័យបន្ទាប់បន្សំ៖** ទិន្នន័យដែលទទួលបានតាមរយៈឯកសារ-កាលប្បវត្តិ ដែលសហគមន៍បានរក្សាទុកដូចជា ច្បាប់ ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្ដីសម្រេច បទបញ្ជា ដីកា លក្ខន្តិកៈ និងរបាយការណ៍ផ្សេងៗទៀតនៅខណ្ឌរដ្ឋបាលព្រៃឈើកំពត ដែលទាក់ទងទៅនឹងដំណើរការនៃគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺធ្វើឡើងនៅក្នុងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ដែលស្ថិតនៅភូមិព្រៃយ៉ាវ ឃុំស្រែក្នុង ស្រុកជុំគីរី ខេត្តកំពត។ ការស្រាវជ្រាវនេះគឺផ្ដោតសំខាន់ទៅលើ ដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន។

**ក. កម្មវត្ថុនៃការស្រាវជ្រាវ៖**

ដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន គឺធ្វើការសិក្សាស្រាវជ្រាវដោយស្ថិតនៅភូមិព្រៃយ៉ាវ ឃុំស្រែក្នុង ស្រុកជុំគីរី ខេត្តកំពត។

**ខ. គោលដៅនៃការស្រាវជ្រាវ៖**

- សិក្សាស្វែងយល់អំពីការកកើតនូវសហគមន៍ព្រៃឈើនៅប្រទេសកម្ពុជា។
- សិក្សាពីលក្ខណៈទូទៅរបស់សហគមន៍ព្រៃឈើ។
- សិក្សាពីដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន។
- យល់ដឹងពីអត្ថប្រយោជន៍ និងហានិភ័យនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន។
- ដើម្បីដឹងអំពីប្រភេទឈើព្រៃមានក្នុងសហគមន៍ព្រៃឈើ ដែលសមាជិកអាចទាញយកផលពីវាបាន។
- ដើម្បីធ្វើសកម្មភាពអភិវឌ្ឍ និងប្រើប្រាស់ធនធានព្រៃឈើ ប្រកបដោយនិរន្តរភាពនៅក្នុងព្រៃសហគមន៍

**គ. លក្ខខណ្ឌជាក់ស្ដែង៖**

- ពេលវេលានៃការស្រាវជ្រាវ៖ ការសិក្សាស្រាវជ្រាវគឺនៅក្នុងចន្លោះឆ្នាំ២០០៩ ដល់២០១៩។
- តំបន់ទិសដៅ៖ ការសិក្សាស្រាវជ្រាវធ្វើឡើងនៅឃុំស្រែក្នុង ស្រុកជុំគីរី ខេត្តកំពត។
- ក្រុមគោលដៅ៖ រដ្ឋបាលព្រៃឈើថ្នាក់កណ្ដាល និងនាយកដ្ឋានសហគមន៍ព្រៃឈើជាអ្នកកំណត់គោលនយោបាយ, ខណ្ឌរដ្ឋបាលព្រៃឈើកំពត និងគណៈកម្មការគ្រប់គ្រងសហគមន៍ជាអ្នកអនុវត្តគោលនយោបាយ ចំណែកឯប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានជាអ្នកទទួលផលប្រយោជន៍ពីការបង្កើត និងគ្រប់គ្រងព្រៃសហគមន៍។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះប្រធានបទនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៣ ជំពូកសំខាន់ៗក្នុងរួមមាន៖

សេចក្តីផ្តើម

ជំពូកទី១ ៖ រំលឹកទ្រឹស្តី

ជំពូកទី២ ៖ ស្ថានភាពទូទៅនៃសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

ជំពូកទី៣ ៖ ដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៧. ប្រតិទិននៃដំណាក់កាលស្រាវជ្រាវ

| កាលបរិច្ឆេទ | បរិយាយ | ទីកន្លែង |
|---|---|---|
| **ថ្ងៃទី១០ មករា ២០២០** | ជ្រើសរើសប្រធានបទស្រាវជ្រាវបណ្តោះអាសន្ន | ស.ភ.ន.វ.ស |
| **ថ្ងៃទី១៥ មករា ២០២០** | ជ្រើសរើស និងស្នើសុំសាស្ត្រាចារ្យណែនាំ | ស.ភ.ន.វ.ស |
| **ថ្ងៃទី១៥ កុម្ភៈ ២០២០** | ប្រគល់ប្រធានបទស្រាវជ្រាវទៅសាលា | ស.ភ.ន.វ.ស |
| **ខែកុម្ភៈ ឆ្នាំ២០២០** | ប្រមូលឯកសារនានាដែលពាក់ព័ន្ធនឹងប្រធានបទ | បណ្ណាល័យ |
| **ខែមីនា ឆ្នាំ២០២០** | រៀបចំឧបករណ៍ប្រមូលព័ត៌មាន (ឧបករណ៍ស្រាវជ្រាវ) | បណ្ណាល័យ |
| **ខែមេសា ឆ្នាំ២០២០** | ចុះសិក្សា ស្រាវជ្រាវ ប្រមូលឯកសារនានា | ខ.វ.ព.កំពត |
| **ខែឧសភា ឆ្នាំ២០២០** | ចុះសិក្សា ស្រាវជ្រាវ ប្រមូលទិន្នន័យបឋម | សហគមន៍ព្រៃឈើ |
| **ខែសីហា ឆ្នាំ២០២០** | វិភាគទិន្នន័យ | សហគមន៍ព្រៃឈើ |
| **ខែកញ្ញា ឆ្នាំ២០២០** | រៀបចំសរសេររបាយការណ៍ស្រាវជ្រាវ | បណ្ណាល័យ |
| **ខែតុលា ឆ្នាំ២០២០** | ពិនិត្យរបាយការណ៍ស្រាវជ្រាវ | បណ្ណាល័យ |
| **ថ្ងៃទី៣០ វិច្ឆិកា ២០២០** | ប្រគល់របាយការណ៍ដល់សាស្ត្រាចារ្យណែនាំ ដើម្បីពិនិត្យ (លើកទី១) | ស.ភ.ន.វ.ស |
| **ខែធ្នូ ឆ្នាំ២០២១** | កែលម្អរបាយការណ៍ស្រាវជ្រាវ | បណ្ណាល័យ |
| **ថ្ងៃទី១៣ ធ្នូ ២០២០** | ប្រគល់របាយការណ៍ដល់សាស្ត្រាចារ្យណែនាំ ដើម្បីពិនិត្យ (លើកទី២) | ស.ភ.ន.វ.ស |
| **ខែធ្នូ ឆ្នាំ២០២០** | កែលម្អរបាយការណ៍ស្រាវជ្រាវ | បណ្ណាល័យ |
| **ថ្ងៃទី១៧ ធ្នូ ២០២០** | សាស្ត្រាចារ្យណែនាំឯកភាពលើរបាយការណ៍ស្រាវជ្រាវ | ស.ភ.ន.វ.ស |
| **ថ្ងៃទី២៦ ធ្នូ ២០២០** | ប្រគល់របាយការណ៍ស្រាវជ្រាវជូនដល់សាលា | ស.ភ.ន.វ.ស |

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. អ្វីទៅជាការគ្រប់គ្រង ?

### ១.១.១. និយមន័យនៃការគ្រប់គ្រង

ពាក្យថា **ការគ្រប់គ្រង** មានន័យយ៉ាងទូលំទូលាយគឺអាស្រ័យទៅតាមការអនុវត្ត និងការបកស្រាយដោយមនុស្ស នៅក្នុងវិស័យផ្សេងៗនៃការងារ។ ជួនកាលគេប្រើពាក្យ ការគ្រប់គ្រង នេះសម្រាប់ពណ៌នាពីសកម្មភាពនៃអ្នកដឹកនាំ និងអ្នកចាត់តាំងការងារតាមបណ្តាស្ថាប័ន ឬអង្គភាពនានា។ ការគ្រប់គ្រងអង្គភាព ឬស្ថាប័នមួយជាដំណើរការប្រើប្រាស់ ដើម្បីដឹកនាំការងាររបស់ខ្លួន និងដើម្បីឱ្យប្រាកដថាបុគ្គលិក និងប្រភពធនធានផ្សេងទៀតរបស់អង្គភាព ត្រូវបានប្រើប្រាស់តាមរបៀបត្រឹមត្រូវដោយមានប្រសិទ្ធភាព ប្រកបដោយសន្សំសំចៃសម្រេចបាននូវគោលដៅរបស់អង្គភាព។ ការគ្រប់គ្រងបង្កើតឱ្យមានរបៀបរៀបរយ និងស៊ីសង្វាក់គ្នារួមមានការធ្វើផែនការ ការធ្វើគម្រោងថវិកា ការបង្កើតរបៀបវារៈ ការធ្វើកាលវិភាគ ការប្រើប្រាស់ធនធាន ការរៀបចំចាត់ចែង ការរៀបចំបុគ្គលិក ដោយបង្កើតឱ្យមានរចនាសម្ព័ន្ធ ការបង្កើតការងារឱ្យបុគ្គលិក ការរៀបចំបទបញ្ជា នីតិវិធី ការត្រួតពិនិត្យ ការដោះស្រាយបញ្ហា ដែលរួមមានការរៀបចំឱ្យមានការលើកទឹកចិត្តទៅដល់បុគ្គលិក ការបង្កើតឱ្យមានការដោះស្រាយវិវាទដោយប៉ិនប្រសព្វ ការចាត់ចែងវិធានការកែតម្រូវ និងការសម្របសម្រួលនូវបញ្ហា[1]។

"ការគ្រប់គ្រង គឺជាសំណុំនៃគោលការណ៍ទាក់ទងទៅនឹងមុខងាររៀបចំផែនការ ការបែងចែក ការដឹកនាំ និងការត្រួតពិនិត្យ ដោយអនុវត្តគោលការណ៍ទាំងនេះក្នុងការប្រើប្រាស់ធនធានរូបវន្ត ហិរញ្ញវត្ថុ មនុស្ស និងធនធានពត៌មានប្រកបដោយប្រសិទ្ធភាព និងសាកសិទ្ធិភាពដើម្បីសំរេចគោលដៅរបស់អង្គភាព"[2]។ ជាមួយគ្នានោះ ការគ្រប់គ្រង គឺសំដៅដល់ការអនុវត្តការចាត់ចែង និងគ្រប់គ្រងមន្ត្រី ដើម្បីសម្រេចនូវលទ្ធផលរំពឹងទុករបស់មន្ត្រី និងគោលដៅរបស់អង្គភាពរួមមាន ការបែងចែងការងារ ធ្វើផែនការគ្រប់គ្រងធនធានមនុស្ស ការជ្រើសរើស ការតែងតាំងផ្លាស់ប្តូរ ការសុំលាឈប់ពីក្របខណ្ឌមុខងារសាធារណៈ និងការផ្តល់ការលើកទឹកចិត្តមន្ត្រី[3]។ ការគ្រប់គ្រង គឺជាប្រព្រឹត្តលើការត្រួតពិនិត្យលើវត្តការងារលើសកម្មភាពផ្ទាល់របស់នរណាម្នាក់ ការទទួលខុសត្រូវក្នុងតួនាទីម្នាក់ៗ និងជាការដាក់បញ្ចូលមានរដ្ឋបាល និងមានការពាក់ព័ន្ធទៅនឹងការរៀបចំឱ្យមានអង្គការចាត់តាំង ដោយធ្វើយ៉ាងណាឱ្យសម្រេចបានគោលបំណងជាអតិបរមា និងមានលទ្ធភាពល្អប្រសើរ ដើម្បីគ្រប់គ្រងឱ្យបានល្អ អ្នកត្រូវពិនិត្យមើលអ្វីជាអាទិភាពរបស់អ្នកឱ្យបានជាប្រចាំគឺដូចអ្នកដាក់ការធ្វើវិនិយោគដែរ។

[1] អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, *ជំនាញនៃការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់អ្នកគ្រប់គ្រងជាន់ខ្ពស់* (ភ្នំពេញ៖ ២០១០), ២៦។

[2] https://www.managementstudyhq.com/functions-of-management.html (ចូលទស្សនាថ្ងៃទី២ មេសា ២០២០)។

[3] ក្រសួងមុខងារសាធារណៈ, *ការកែលំអការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស* (ភ្នំពេញ៖ ២០១៤), ៦៨។

ការគ្រប់គ្រងយុទ្ធសាស្ត្រ អាចត្រូវបានកំណត់ថាជាសិល្បៈ និងវិទ្យាសាស្ត្រនៃការបង្កើតការអនុវត្ត និងវាយតម្លៃការសំរេចចិត្តឆ្លងកាត់មុខងារ ដែលអាចឱ្យអង្គភាពមួយសំរេចគោលបំណងរបស់ខ្លួន ដូចនិយមន័យនេះមានន័យថាការគ្រប់គ្រងយុទ្ធសាស្ត្រ គឺផ្តោតលើការរួមបញ្ចូលការគ្រប់គ្រងទីផ្សារ ហិរញ្ញវត្ថុ និងគណនេយ្យផលិតកម្ម ប្រតិបត្តិការស្រាវជ្រាវ និងការអភិវឌ្ឍ និងប្រព័ន្ធព័ត៌មានដើម្បីទទួលបានភាពជោគជ័យរបស់អង្គភាព ដែលគោលបំណងនៃការគ្រប់គ្រងយុទ្ធសាស្ត្រ គឺដើម្បីកេងចំណេញ និងបង្កើតឱកាសថ្មី ប្លែកសម្រាប់ថ្ងៃស្អែក។ ការធ្វើផែនការរយៈវែង ព្យាយាមធ្វើឱ្យប្រសើរឡើងសម្រាប់ថ្ងៃស្អែកនិន្នាការនាពេលបច្ចុប្បន្ននេះ[4]។

### ១.១.២. កម្រិតនៃការគ្រប់គ្រង

ការគ្រប់គ្រងបែងចែកជា ៣ ថ្នាក់ក្នុងនោះរួមមាន[5]៖

**រូបភាពទី១**

Level of Management




ប្រភព: https://businessjargons.com/management.html

- ការគ្រប់គ្រងថ្នាក់លើ (Top Level Management)៖ នេះគឺជាកម្រិតខ្ពស់បំផុតនៅក្នុងឋានានុក្រមរបស់អង្គភាព ដែលរួមមានក្រុមប្រឹក្សាភិបាលនិងនាយកប្រតិបត្តិ។ ពួកគេទទួលខុសត្រូវក្នុងការកំណត់គោលបំណងបង្កើតផែនការយុទ្ធសាស្ត្រនិងគោលនយោបាយ។
- ការគ្រប់គ្រងថ្នាក់កណ្តាល (Middle Level Management)៖ វាគឺជាកម្រិតទីពីរនិងសំខាន់បំផុតនៅក្នុងដំណើរក្រុមហ៊ុនព្រោះវាបង្កើតជាការផ្សារភ្ជាប់គ្នារវាងថ្នាក់ដឹកនាំកំពូលនិងថ្នាក់ក្រោម។ វារួមបញ្ចូលទាំងប្រធានផ្នែកនិងប្រធានផ្នែកនិងអ្នកគ្រប់គ្រងដែលទទួលខុសត្រូវក្នុងការអនុវត្តនិងគ្រប់គ្រងផែនការនិងយុទ្ធសាស្ត្រដែលត្រូវបានរៀបចំឡើងដោយនាយកប្រតិបត្តិជាន់ខ្ពស់។

---

[4] Fred R. David និង Forest R. David, Strategic Management [គ្រប់គ្រងយុទ្ធិសាស្ត្រ] 15th Edition (USA: Courier Kendallville, 2015), 39។

[5] https://businessjargons.com/management.html (ចូលទស្សនាថ្ងៃទី៦ មេសា ២០២០)។

– ការគ្រប់គ្រងថ្នាក់ទាប (Lower Level Management)៖ បើមិនដូច្នេះទេគេហៅថា ការគ្រប់គ្រងកម្រិតមុខងារ ឬប្រតិបត្តិការ។ វារួមបញ្ចូលទាំងអ្នកគ្រប់គ្រងជួរទីមួយអ្នកមើលការខុសត្រូវអ្នកមើលការខុសត្រូវ។ ដោយសារការគ្រប់គ្រងកម្រិតទាបមានអន្តរកម្មផ្ទាល់ជាមួយកម្មករ វាដើរតួនាទីយ៉ាងសំខាន់នៅក្នុងអង្គការព្រោះវាជួយក្នុងការកាត់បន្ថយពេលវេលាខ្ជះខ្ជាយ និងពេលវេលាទំនេររបស់កម្មករធ្វើឱ្យប្រសើរឡើងនូវគុណភាព និងបរិមាណនៃទិន្នផល។

### ១.១.៣. មុខងារនៃការគ្រប់គ្រង

មុខងារមូលដ្ឋានទាំងបួននៃការគ្រប់គ្រង គឺជាការដំណើរការនៃការធ្វើឱ្យសម្រេចនូវគោលដៅរបស់អង្គភាព ឬស្ថាប័នប្រកបដោយប្រសិទ្ធភាពតាមរយៈមនុស្សដទៃ និងតាមរយៈការប្រើប្រាស់មុខងារចម្បងៗ[6]។ ការបំពេញមុខងារនៃការគ្រប់គ្រង និងតម្រូវការនៃមុខងារទាំងនេះអាចដើរតួនាទីតាមពេលផ្សេងៗគ្នារបស់អ្នកគ្រប់គ្រង និងភាពខុសគ្នាវាអាស្រ័យទៅតាមកម្រិតថ្នាក់ និងមុខងារនៃការគ្រប់គ្រង។ មុខងារទាំងនេះត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយគ្នាក្នុងការបង្កើតការប្រតិបត្តិ និងការសំរេចគោលដៅរបស់អង្គភាព។ ដើម្បីទទួលបានជោគជ័យការគ្រប់គ្រងត្រូវការអនុវត្តតាមមុខងារទាំងបួននៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ។

**រូបភាពទី២**

Function of Management




ប្រភព: http://hrmpractice.com/functions-of-management/

[6] ជា ចំរើន, *មូលដ្ឋានគ្រឹះនៃភាពជាអ្នកដឹកនាំ* (ភ្នំពេញ៖ ២០១២), ២៤។

**១.១.៣.១. ការធ្វើផែនការ** (Planning)

ការធ្វើផែនការ វាគឺជាមុខងារដំបូង និងសំខាន់បំផុតនៃការគ្រប់គ្រង ពោលគឺត្រូវធ្វើការសម្រេចចិត្តជាមុននូវអ្វីដែលត្រូវធ្វើនាពេលអនាគត វារួមបញ្ចូលនូវការបង្កើតគោលនយោបាយ បង្កើតគោលដៅ កំណត់សកម្មភាព និងសកម្មភាពផ្សេងៗទៀត ក្នុងដំណាក់កាលរៀបចំផែនការ ការគ្រប់គ្រងធ្វើការសំរេចចិត្តជាយុទ្ធសាស្ត្រ ដើម្បីកំណត់ទិសដៅសម្រាប់អង្គភាព ដោយធ្វើការជ្រើសរើសសកម្មភាពដែលល្អបំផុត។

**១.១.៣.២. ការរៀបចំចាត់តាំង** (Organizing)

ការរៀបចំចាត់តាំង ជាមុខងារនៃការគ្រប់គ្រងដែលផ្តោតទៅលើការបែងចែកធនធាន និងធនធានមិនមានមនុស្សឱ្យស្របទៅនឹងការអនុវត្តផែនការ ដើម្បីឱ្យមានភាពជោគជ័យ។ មុខងារចាត់តាំងក៏ដូចជាមុខងារផែនការដែរ គឺទាមទារឱ្យអ្នកគ្រប់គ្រងត្រូវតែយល់ដឹង និងវិភាគឱ្យបានល្អិតល្អន់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន នៅពេលផែនការត្រូវបានបង្កើតឡើង ជំហានបន្ទាប់គឺរៀបចំសកម្មភាព និងធនធានដូចជាក្នុងការកំណត់ភារកិច្ច ចាត់ថ្នាក់ពួកគេចាត់ចែងភារកិច្ចដល់អ្នកក្រោមបង្គាប់និងបែងចែកធនធាន។

**១.១.៣.៣. បុគ្គលិក** (Staffing)

ទាក់ទងនឹងការជួលបុគ្គលិកសម្រាប់អនុវត្តសកម្មភាពផ្សេងៗរបស់អង្គភាព ដែលត្រូវកំណត់ឱ្យបានច្បាស់លាស់នៃសកម្មភាពការងារនីមួយៗ ដើម្បីឱ្យបុគ្គលិកអនុវត្តតាមគោលការណ៍នៃការចាត់តាំងក្នុងអង្គភាព ដើម្បីធានាថាមនុស្សត្រូវបានតែងតាំងឱ្យធ្វើការត្រឹមត្រូវ។

**១.១.៣.៤. ការដឹកនាំ** (Directing)

ការដឹកនាំ ជាមុខងារនៃការគ្រប់គ្រង ដែលធ្វើឡើងដោយការតម្រង់ទិស និងការលើកទឹកចិត្ត ដែលធ្វើឱ្យមានឥទ្ធិពលទៅលើសមាជិកក្នុងអង្គភាព ឬស្ថាប័ននៅក្នុងការអនុវត្តការងារ ដើម្បីឱ្យអង្គភាព ឬស្ថាប័នសម្រេចគោលបំណងរបស់អង្គភាព ឬស្ថាប័ន។ វាជាភារកិច្ចរបស់អ្នកគ្រប់គ្រងដើម្បីដឹកនាំ និងលើកទឹកចិត្តដល់អ្នកក្រោមបង្គាប់ ដើម្បីធានាថាពួកគេធ្វើការក្នុងទិសដៅត្រឹមត្រូវរហូតមកដល់ពេលដែលគោលបំណងរបស់អង្គភាពមានការយកចិត្តទុកដាក់។

**១.១.៣.៥. ការត្រួតពិនិត្យ** (Controlling)

ការត្រួតពិនិត្យ ជាមុខងារនៃការគ្រប់គ្រងដែលត្រូវតាមដានការអនុវត្តជាក់ស្តែងរបស់បុគ្គលិក ថាតើគេបានអនុវត្តនោះទៅតាមផែនការដែលបានគ្រោងទុកដែរឬទេ? ការត្រួតពិនិត្យគឺជាមុខងារទីបួននៃការគ្រប់គ្រង គឺជាការស្ទង់ និងវិភាគជាបន្តបន្ទាប់នូវការអនុវត្តជាក់ស្តែង ហើយប្រៀបធៀបទៅនឹងស្តង់ដារ ដែលបានបង្កើតឡើងក្នុងពេលរៀបចំផែនការ។ មុខងារត្រួតពិនិត្យនៃការគ្រប់គ្រងពាក់ព័ន្ធនឹងជំហានមួយចំនួន ដែលត្រូវធ្វើដើម្បីធ្វើឱ្យប្រាកដថាការអនុវត្តរបស់និយោជិកគឺដូចទៅនឹងផែនការ។

## ១.២. ទស្សនៈអំពីចរិយាធម៌នៃការគ្រប់គ្រង

នៅទសវត្សឆ្នាំ ១៩៦០ ចិត្តវិទូសង្គមលោក Douglas McGregor បានបង្កើតទ្រឹស្ដីផ្ទុយគ្នាពីរ ដែលពន្យល់អំពីជំនឿរបស់អ្នកគ្រប់គ្រងអំពីអ្វី ដែលជម្រុញប្រជាជនអាចជះឥទ្ធិពលដល់របៀបរៀបចំរបស់ពួកគេ។ គាត់បានដាក់ឈ្មោះទ្រឹស្ដីX និងទ្រឹស្ដីY។ ទ្រឹស្ដីទាំងនេះនៅតែមានសារៈសំខាន់សូម្បីតែសព្វថ្ងៃនេះ។ ទ្រឹស្ដី X និងទ្រឹស្ដីY ត្រូវបានពន្យល់ជាលើកដំបូងដោយលោក Douglas McGregor នៅក្នុងសៀវភៅរបស់គាត់គឺ" The Human Side of Enterprise" ហើយពួកគេសំដៅទៅលើការគ្រប់គ្រងពីរបែបភាពផ្ដាច់ការ (ទ្រឹស្ដីX) និងការចូលរួម (ទ្រឹស្ដីY)[7]។

### ១.២.១. សម្មិតកម្មនៃទ្រឹស្ដី X "អ៊ិច"

ក្នុងទ្រឹស្ដី X គឺផ្ដោតទៅលើបុគ្គលិកដែលខ្ជិល ដែលអ្នកគ្រប់គ្រងទ្រឹស្ដី X មានទំនោរទៅរកទស្សនៈទុទិដ្ឋិនិយមចំពោះប្រជាជនរបស់ពួកគេ ហើយសន្មត់ថាពួកគេជាមនុស្សគ្មានការងារធ្វើ និងមិនចូលចិត្តការងារ ជាលទ្ធផលពួកគេគិតថាសមាជិកក្រុមត្រូវការឱ្យមានការលើកទឹកចិត្ត ផ្ដល់រង្វាន់ ឬដាក់ទណ្ឌកម្មជាប្រចាំ ធ្វើឱ្យប្រាកដថាពួកគេបំពេញភារកិច្ចរបស់ពួកគេ ដើម្បីឱ្យគេធ្វើការសម្រាប់សម្រេចទិសដៅរបស់អង្គភាព ភាគច្រើនមិនមែនចូលចិត្តការទទួលខុសត្រូវ និងមានមហិច្ឆិតាតិចតួច ចូលចិត្តសម្ងំសុខ។

### ១.២.២. សម្មិតកម្មនៃទ្រឹស្ដី Y "វ៉ាយ"

ក្នុងទ្រឹស្ដី Y គឺផ្ដោតទៅលើបុគ្គលិកដែលឧស្សាហ៍ ចូលចិត្តការងារ ប្រឹងប្រែងខាងកម្លាំងកាយ និងស្មារតីដែលរួមបញ្ចូល គឺជាសភាពនៃធម្មជាតិដូចជាការលេង ឬសំរាក។ មនុស្សគ្រប់ៗគ្នាដឹកនាំខ្លួនគេ និងត្រួតពិនិត្យខ្លួនគេ ដើម្បីឈានទៅរកទិសដៅ ដែលគេប្ដេជ្ញានឹងធ្វើឱ្យបានជោគជ័យ។ ការត្រួតពិនិត្យ ឬការគំរាមកំហែងដាក់ទណ្ឌកម្មពីខាងក្រៅមិនមែនជាមធ្យោបាយតែមួយទេសម្រាប់ឱ្យគេប្រឹងដើម្បីសម្រេចទិសដៅ។ ការប្ដេជ្ញាសម្រេចទិសដៅ គឺអាស្រ័យទៅលើរង្វាន់ដែលបំពេញបំណងតម្រូវការឱ្យគេចូលចិត្តស្រឡាញ់ និងយកចិត្តទុកដាក់។ កាលណាមានលក្ខខណ្ឌ មានអំណោយផល មនុស្សមិនគ្រប់គ្រាន់រៀនដើម្បីទទួលការខុសត្រូវទេ តែថែមទាំងស្វែងរកការទទួលខុសត្រូវទៀតផង។ មនុស្សជាច្រើនមានសមត្ថភាពខាងការបង្កើត ខាងការឆ្នៃប្រឌិតគំនិតផ្ដើម និងបង្កើតនូវអ្វីៗដែលថ្មីនៅពេលដោះស្រាយបញ្ហាក្នុងអង្គភាព។

សក្ដានុពលភាពខាងប្រាជ្ញានៃបុគ្គលិកបានប្រើប្រាស់តែមួយផ្នែកនៅក្នុងអង្គភាព។ អ្នកគ្រប់គ្រងតាមទ្រឹស្ដី X ដូចជា ការរៀបចំផលិតកម្ម ការដឹកនាំមនុស្ស ការត្រួតពិនិត្យ ការបញ្ចុះបញ្ចូល ការជូនរង្វាន់ ការដាក់ទណ្ឌកម្ម ចំពោះកម្លាំងការងារបានទទួលយកមុខការប្រតិបត្តិ។ អ្នកគ្រប់គ្រងតាមទ្រឹស្ដី Y ដូចជាការខំប្រឹង

7 Douglas McGregor, *The Human Side of Enterprise* [ផ្នែកខាងមនុស្សនៃសហគ្រាស] (UK: Cambridge University, 2006), 102។

បង្កើតឱ្យមានឱកាសល្អៗ សម្រាប់កម្មករទាំងអស់ដើម្បីជំរុញឱ្យគេទទួលខុសត្រូវលើខ្លួនគេ ដើម្បីសម្រេចគោលដៅអង្គភាពចាត់តាំង។

## ១.៣. សិទ្ធិអំណាចក្នុងការគ្រប់គ្រង

សិទ្ធិអំណាចត្រូវបានផ្តល់ឱ្យទៅបុគ្គលិក ដើម្បីធ្វើការសម្រេចចិត្ត និងអនុវត្តសកម្មភាពការងារដោយមិនចាំបាច់មានការសម្រេចចិត្តពីថ្នាក់លើ ដែលអំណាចមានបីប្រភេទដូចខាងក្រោម[8]៖

**ក. អំណាចខ្សែបញ្ជា ៖** អំណាចខ្សែបញ្ជា ឬខ្សែនៃអំណាច គឺជាការបញ្ជាជាផ្លូវការ ដែលកំណត់ឡើងដោយខ្សែអំណាចពីថ្នាក់កំពូលដោយផ្ទាល់ ដល់ថ្នាក់ក្រោមក្នុងអង្គភាព។

**ខ. អំណាចបុគ្គលិក ៖** អំណាចបុគ្គលិក គឺជាអំណាចដែលគាំទ្រជួយ និងផ្តល់ដំបូន្មានផ្សេងៗ ចំពោះបុគ្គលិកកាន់ការងារតាមខ្សែនៃអំណាច ដែលមានកំណត់នៅក្នុងរចនាសម្ព័ន្ធរបស់អង្គភាព។

**គ. អំណាចមុខងារ ៖** អំណាចមុខងារ គឺជាសិទ្ធិតាមដែនកំណត់ការងារដែលកំណត់ក្នុងបំណែងការងាររបស់បុគ្គលិក ដែលតម្រង់ទិសបុគ្គលិកឱ្យអនុវត្តការងារទៅតាមការងារជាក់លាក់។

## ១.៤. ការធ្វើប្រតិភូកម្មនៃការគ្រប់គ្រងសកម្មភាពការងារ

### ១.៤.១. អ្វីជាការធ្វើប្រតិភូកម្ម?

ការធ្វើប្រតិភូកម្ម គឺជាការផ្ទេរសមត្ថកិច្ចផ្លូវការពីអ្នកខាងលើទៅអ្នកក្រោមបង្គាប់ បុគ្គលិកនោះត្រូវបានគេផ្តល់សិទ្ធិអំណាចអោយធ្វើការងារជួសប្រធាន ឯប្រធាននៅតែទទួលខុសត្រូវលទ្ធផលការងារនោះដដែល[9]។ ការផ្ទេរសមត្ថកិច្ច គឺជាទំនាក់ទំនងរវាងមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដែលតម្រូវឱ្យមានការទុកចិត្ត ការប្តេជ្ញាចិត្តលើការងារ និងការព្រមព្រៀងរវាងអ្នកគ្រប់គ្រង និងបុគ្គលិក។

### ១.៤.២. ការធ្វើប្រតិភូកម្មការងារ

ការធ្វើប្រតិភូកម្ម ឬការផ្ទេរសមត្ថកិច្ចនេះ រួមមាន៖

**ក. អំណាច ៖** គឺជាសមត្ថភាពប្រើឥទ្ធិពល ដើម្បីឱ្យអ្នកដទៃធ្វើកិច្ចការអ្វីមួយ។

**ខ. សមត្ថកិច្ច ៖** គឺជាអំណាចចាប់បង្ខំអោយគេអនុវត្តច្បាប់ និងធ្វើតាមបញ្ជាហើយរំពឹងទុកនូវការគោរព។

**គ. ការទទួលខុសត្រូវ ៖** គឺទាក់ទងទៅនឹងការទទួលខុសត្រូវក្នុងការសម្រេចចិត្ត មានកាតព្វកិច្ច ករណីកិច្ច ហើយអនុវត្តការងារនោះឱ្យបានសមហេតុផល ពោលគឺវាទាក់ទងទៅនឹងការធ្វើការប្រាស្រ័យទាក់ទងគ្នា និងការដឹងពីតួនាទីទំនាក់ទំនងជាមួយអ្នកដទៃ។

---

[8] សោម បូនី, *បទបង្ហាញស្តីពីជំនាញគ្រប់គ្រង*, សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច, ឆ្នាំ២០១៨, ២១។

[9] អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, *ជំនាញនៃការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់អ្នកគ្រប់គ្រងជាន់ខ្ពស់*, (ភ្នំពេញ៖ ២០១០), ៧៦។

**ឃ. ការផ្តល់សិទ្ធិអំណាច ៖** គឺសំដៅទៅដល់ការលើកទឹកចិត្ត និងការផ្តល់សិទ្ធិអំណាចឱ្យបុគ្គលិកនោះមានគំនិតផ្តួចផ្តើម ដើម្បីបង្កើនប្រសិទ្ធភាពការងារ កាត់បន្ថយការចំណាយ និងពង្រឹងគុណភាពផលិតផល និងសេវាអតិថិជន។

**១.៥. សហគមន៍ព្រៃឈើ**

សហគមន៍ព្រៃឈើ សំដៅដល់ព្រៃគ្រប់គ្រងដោយប្រជាសហគមន៍ស្ម័គ្រចិត្តចងក្រងប្រមូលផ្តុំជាក្រុមក្រោមកិច្ចព្រមព្រៀងពីរដ្ឋបាលព្រៃឈើ ដើម្បីធ្វើសកម្មភាពអភិវឌ្ឍន៍ និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាពនៅក្នុងព្រៃសហគមន៍ ដោយអនុវត្តតាមបទប្បញ្ញត្តិច្បាប់ស្តីពីព្រៃឈើ[10]។ សហគមន៍ព្រៃឈើ គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ[11] មានន័យថាដីសហគមន៍នេះមិនអាចលក់ ផ្តល់អាជ្ញាប័ណ្ណជាដីសម្បទានសេដ្ឋកិច្ច (ELCs) បានជាដាច់ខាត។ ច្បាប់ស្តីពីព្រៃឈើផ្តល់នូវមូលដ្ឋានច្បាប់សម្រាប់សហគមន៍ជនបទក្នុងការប្រើប្រាស់ និងជួយគ្រប់គ្រងព្រៃឈើ តាមរយៈសហគមន៍ព្រៃឈើ។ អនុក្រឹត្យឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ បានកំណត់ច្បាប់សម្រាប់ការបង្កើត ការគ្រប់គ្រង និងការប្រើប្រាស់សហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជា។ កម្មវិធីព្រៃឈើជាតិ មានកម្មវិធីធំៗចំនួន៦ ដែលនឹងត្រូវអនុវត្ត និងត្រួតពិនិត្យតាមដានជាង២០ឆ្នាំ[12]៖

- ការបោះបង្គោល ការចាត់ថ្នាក់ និងការចុះបញ្ជីព្រៃឈើ
- ការអភិរក្ស និងការអភិវឌ្ឍធនធានព្រៃឈើ និងជីវៈចម្រុះ
- ការពង្រឹងច្បាប់ និងអភិបាលកិច្ចព្រៃឈើ
- សហគមន៍ព្រៃឈើ
- ការអភិវឌ្ឍសមត្ថភាព និងការស្រាវជ្រាវ
- ការផ្តល់ហិរញ្ញប្បទានព្រៃឈើប្រកបដោយនិរន្តរភាព។

សហគមន៍ជនបទជាច្រើន ពឹងផ្អែកលើព្រៃឈើ យ៉ាងហោចណាស់ជាផ្នែកមួយសម្រាប់ជីវភាពរស់នៅរបស់ពួកគេ។ សំណុំទិន្នន័យអូឌីស៊ីបង្ហាញពីសហគមន៍ព្រៃឈើចំនួន ៣៣៧ ដែលមានទំហំចាប់ពី ១០ហិកតាទៅ ៥,០០០ហិកតា។ គម្រោងមួយចំនួនកំពុងជួយសហគមន៍ ដើម្បីការពារព្រៃឈើ។ ឧទាហរណ៍ នៅខែមីនា ឆ្នាំ២០១៨ គម្រោងរយៈពេល៥ឆ្នាំ ស្មើនឹងទឹកប្រាក់ចំនួន ៣,៤លានដុល្លារអាមេរិក ដែលទទួលបានការគាំទ្រដោយសហភាពអឺរ៉ុប និងអង្គការ WWF ត្រូវបានបង្កើតឡើងដើម្បីជួយដល់សហគមន៍ព្រៃឈើនៅក្នុងខេត្ត

[10] អនុក្រឹត្យស្តីពីកាគ្រប់គ្រងសហគមន៍ព្រៃឈើ, លេខ ៧៩ អនក្រ.បក, ២០០៣, មាត្រា៥ ចំណុចទី១០។

[11] អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ, លេខ ៧៩ អនក្រ.បក, ២០០៣, មាត្រា៣។

[12] ក្រសួងផែនការ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨* (ភ្នំពេញ៖ ២០១០), ១៣៤។

មណ្ឌលគិរី។ គម្រោងនេះមានគោលបំណងជួយដល់ ២០០០គ្រួសារ ដែលរស់នៅក្នុង ៣៤ភូមិ នៅក្នុងតំបន់ការពារចំនួនពីរ ដើម្បីការពារព្រៃឈើរបស់ពួកគាត់ពីសម្ពាធខាងក្រៅ[13]។

### **១.៥.១. ទស្សនៈនៃសហគមន៍ព្រៃឈើ**

សហគមន៍ព្រៃឈើ គឺជាយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពតាមរយៈការចូលរួមរបស់ប្រជាជននៅជនបទ ដោយការរៀបចំទិសដៅឱ្យប្រជាជននៅជនបទជាចំណុចសំខាន់ៗបំផុត ក្នុងការគ្រប់គ្រងព្រៃឈើ និងការធានាឱ្យបានថា ប្រជាជននៅជនបទទទួលបានផលប្រយោជន៍សមស្របពីការគ្រប់គ្រងព្រៃឈើ។ ទស្សនាទានអំពីសហគមន៍ព្រៃឈើ គឺជាស្វែងរកគោលការណ៍ដែលសហគមន៍មូលដ្ឋានអាចធ្វើការគ្រប់គ្រងធនធានឱ្យមានផលប្រយោជន៍ក្នុងរយៈពេលយូរអង្វែង ហើយក្នុងរយៈពេលនៃផលប្រយោជន៍យូរអង្វែងនេះត្រូវមានភាពស្មើគ្នាជាមួយនិរន្តរភាពនៃធនធាន។ មានន័យថា សហគមន៍ព្រៃឈើបំពេញបន្ថែម និងបង្កើនយុទ្ធវិធីគ្រប់គ្រងព្រៃឈើ និងរួមចំណែកក្នុងការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព។ ព្រៃសហគមន៍ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសេដ្ឋកិច្ច និងដោយធានានិរន្តរភាពដោយសហគមន៍មូលដ្ឋាន ស្របតាមផែនការគ្រប់គ្រងព្រៃសហគមន៍ វិធានសហគមន៍ និងគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ[14]។

### **១.៥.២. ផែនការគ្រប់គ្រងព្រៃសហគមន៍**

អ្វីទៅជាផែនការគ្រប់គ្រងព្រៃសហគមន៍? ផែនការគ្រប់គ្រងព្រៃសហគមន៍ ត្រូវបានរៀបចំឡើងដោយសហគមន៍មូលដ្ឋាន និងមានការយល់ព្រមដោយថ្នាក់ខណ្ឌរដ្ឋបាលព្រៃឈើ[15]។ ផែនការគ្រប់គ្រងព្រៃសហគមន៍ សំដៅដល់ឯកសារមួយដែលរៀបចំឡើងដោយសហគមន៍ព្រៃឈើ និងមានការឯកភាពពីរដ្ឋបាលព្រៃឈើ ដោយមានការវាយតម្លៃហេតុផលប៉ះពាល់សង្គម និងបរិស្ថាន ព្រមទាំងមានការបញ្ជាក់លំអិតអំពីនីតិវិធី បទបញ្ជា និងវិធានការពាក់ព័ន្ធនឹងការរៀបចំប្រើប្រាស់ព្រៃសហគមន៍ប្រកបដោយនិរន្តរភាព។ ផែនការគ្រប់គ្រងព្រៃសហគមន៍នឹងបញ្ជាក់បន្ថែមក្នុងផ្នែកបន្ទាប់នៃគោលការណ៍ ពិនិត្យឡើងវិញនូវផែនការគ្រប់គ្រងព្រៃសហគមន៍ជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យប្រាកដថាអ្នកពាក់ព័ន្ធទាំងអស់ដែលបានកំណត់ បានចូលរួមក្នុងការគ្រប់គ្រងព្រៃឈើសមស្របនឹងទំហំការងារ។ ពិនិត្យមើលបញ្ហានានា និងពង្រឹងគោលបំណងនៃព្រៃឈើសហគមន៍ ព្រមទាំងប្រមូលផ្តុំរាល់ទិន្នន័យ និងពត៌មាននានាស្តីពីធនធានព្រៃឈើ។ ផែនការគ្រប់គ្រងព្រៃសហគមន៍ គឺជាការវិភាគលើវិធីសាស្ត្រនៃការគ្រប់គ្រងព្រៃឈើ ដោយមានគ្រោងសកម្មភាពសម្រាប់គ្រប់គ្រង និងលទ្ធផលរំពឹងទុក រួមទាំងកំណត់នូវកម្រិតអនុញ្ញាតប្រមូលផលទៅលើប្រភេទធនធានខុសគ្នា ហើយបែងចែកនូវកំរៃ និងផលប្រយោជន៍។ ការពិភាក្សា និងវិភាគលើវិធីសាស្ត្រនៃការគ្រប់គ្រងព្រៃឈើជាមួយសហគមន៍ ដោយជ្រើសរើសនូវវិធីសាស្ត្រ

[13] កាសែតខ្មែរថាមស៍, *ការបើកដំណើរការគម្រោងដើម្បីអភិរក្សធនធានធម្មជាតិនៅខេត្តមណ្ឌលគិរី*, ចេញផ្សាយថ្ងៃទី៣០ មីនា ២០១៨។
[14] ច្បាប់ស្តីពីព្រៃឈើ, លេខ នស/រកម/០៨០២/០១៦. ៣០ កក្កដា ២០០២, មាត្រា៤៣, កថាខណ្ឌ១។
[15] ច្បាប់ស្តីពីព្រៃឈើ, លេខ នស/រកម/០៨០២/០១៦. ៣០ កក្កដា ២០០២, មាត្រា៤៣, កថាខណ្ឌ២។

គ្រប់គ្រងណាមួយដែលពេញចិត្ត និងរៀបចំនូវផែនការគ្រប់គ្រងព្រៃសហគមន៍ ដោយមានបទប្បញ្ញត្តិ កម្រិត អនុញ្ញាតប្រមូលផលលើប្រភេទធនធានខុសគ្នា និងគោលការណ៍ណែនាំ សម្រាប់បែងចែកផលប្រយោជន៍។

ផែនការគ្រប់គ្រងព្រៃសហគមន៍ គឺជាការពិភាក្សា និងផ្ទៀងផ្ទាត់ឡើងវិញនូវផែនការគ្រប់គ្រងព្រៃសហគម ន៍ រួមទាំងលក្ខន្តិកៈនៃគណៈកម្មាធិការព្រៃឈើភូមិ ឬសមាគមសហគមន៍ព្រៃឈើជាមួយសហគមន៍ ព្រមទាំង ផ្ញើផែនការគ្រប់គ្រងព្រៃឈើសហគមន៍ និងលក្ខន្តិកៈនៃគណៈកម្មាធិការព្រៃឈើភូមិ ឬសមាគមសហគមន៍ព្រៃ ឈើទៅឱ្យអាជ្ញាធរពាក់ព័ន្ធ។ បន្ទាប់ពីមានការឯកភាពលើកិច្ចព្រមព្រៀងព្រៃសហគមន៍ គណៈកម្មការគ្រប់គ្រង សហគមន៍ព្រៃឈើ ត្រូវរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ ដោយមានការចូលរួមពីសមាជិកសហគមន៍ ព្រៃឈើទៅតាមនីតិវិធីដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គ.កគ្រប់គ្រងសហគមន៍ព្រៃឈើ។ គណៈកម្មការ គ្រប់គ្រងសហគមន៍ព្រៃឈើ អាចស្នើសុំជំនួយបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ពីរដ្ឋបាល ព្រៃឈើ ស្ថាប័នឬអ្នកមានជំនាញក្នុងការគ្រប់គ្រងព្រៃសហគមន៍។ គណៈកម្មការគ្រប់គ្រងព្រៃសហគមន៍ត្រូវ ដាក់ស្នើផែនការគ្រប់គ្រងព្រៃសហគមន៍ទៅជូនប្រធានរដ្ឋបាលព្រៃឈើ ដើម្បីពិនិត្យសម្រេចតាមរយៈខណ្ឌរដ្ឋបាល ព្រៃឈើ។ ផែនការព្រៃសហគមន៍ ត្រូវមានសុពលភាពស្មើនឹងកិច្ចព្រមព្រៀងព្រៃសហគមន៍[16]។ ផែនការគ្រប់គ្រង ព្រៃសហគមន៍ ត្រូវពិនិត្យឡើងវិញដោយរដ្ឋបាលព្រៃឈើរៀងរាល់៥ឆ្នាំម្តង ឬមុនរយៈពេលន ប្រសិនបើចាំបាច់។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រងគ្រងព្រៃសហគមន៍ ត្រូវមានការចូលរួមពី តំណាងគណៈកម្មការគ្រប់គ្រងសហគមន៍។ រដ្ឋបាលព្រៃឈើអាចតម្រូវឱ្យគណៈកម្មការគ្រប់គ្រងសហគមន៍ ព្រៃឈើ ធ្វើការកែសម្រួលផែនការគ្រប់គ្រងព្រៃសហគមន៍ឡើងវិញឱ្យស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ និងក្រម បច្ចេកទេសគ្រប់គ្រងព្រៃឈើ ដើម្បីធានាដល់និរន្តរភាពនៃព្រៃសហគមន៍។

## ១.៦. គោលនយោបាយរាជរដ្ឋាភិបាលក្នុងការគាំទ្រសហគមន៍ព្រៃឈើ

ដោយការទទួលស្គាល់សក្តានុពលសហគមន៍ព្រៃឈើ សម្រាប់វិភាគទានក្នុងការកែលម្អនៃការគ្រប់គ្រង ព្រៃឈើនៅដើមឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមបទបញ្ញត្តិនយោបាយមួយ ដើម្បីកំណត់ទំហំ និង វិសាលភាពសហគមន៍ព្រៃឈើក្នុងប្រទេស។ ការអភិវឌ្ឍនយោបាយបានធ្វើជាចំបង នៅក្នុងសណ្ឋាននៃការធ្វើ សេចក្តីព្រាងច្បាប់។ ការអភិវឌ្ឍច្បាប់ និងនយោបាយព្រៃឈើ បានពិចារណាជាបន្តបន្ទាប់ក្នុងការបង្កើតបរិយា កាសមួយក្នុងនោះសក្តានុពលនៃសហគមន៍ព្រៃឈើ ជាមធ្យោបាយមួយក្នុងការកែលម្អការគ្រប់គ្រងព្រៃឈើអាច នឹងជួបប្រទះដូចខាងក្រោម[17]៖

[16] អនុក្រឹត្យស្តីពីកាគ្រប់គ្រងសហគមន៍ព្រៃឈើ, លេខ៧៩ អនក្រ.បក, ២០០៣, មាត្រា៣០។

[17] គោលការណ៍ណែនាំសហគមន៍ព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០០០។

1) គួរបង្កើតឱ្យមានលក្ខខណ្ឌទទួលស្គាល់សិទ្ធិរបស់ប្រជាជនមូលដ្ឋាន ដើម្បីឱ្យសហគមន៍នោះបង្ហាញសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើ ជាមួយនឹងសិទ្ធិរបស់អ្នកប្រើប្រាស់ដីព្រៃឈើ។ ប្រយោជន៍ដែលបានមកពីការគ្រប់គ្រងដីព្រៃឈើជូនសហគមន៍ មិនគួរកម្រិតត្រឹមគ្រប់គ្រាន់តែចិញ្ចឹមជីវិតនោះទេ គួរតែអនុញ្ញាតឱ្យសហគមន៍ពឹងផ្អែកជីវភាពរស់នៅរបស់ពួកគេ លើការគ្រប់គ្រងព្រៃឈើដែលឆ្លុះបញ្ចាំងលើមូលដ្ឋានប្រកបដោយនិរន្តរភាព។

2) តួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ ត្រូវកំណត់ឱ្យច្បាស់លាស់ សមស្រប។ ដោយឡែកអាជ្ញាធរ ដែលសម្រេចឱ្យសិទ្ធិប្រើប្រាស់ដីព្រៃជាផ្លូវការដល់សហគមន៍ប្រើប្រាស់ ត្រូវតែកំណត់ឱ្យមាននៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ ដំណើរការពិគ្រោះយោបល់ជាបន្ត បន្ទាប់ក្នុងការរៀបចំគោលលំនាំនេះ អនុគ្រោះដល់ការសម្របសម្រួលដ៏ទូលំទូលាយ ដូចជាព្រៃឈើនៅក្នុងតំបន់ការពារក្រសួងបរិស្ថានមានការទទួលខុសត្រូវដល់ទីបំផុត មន្ទីរបរិស្ថានខេត្ត គួរមានអំណាចសម្រេចឱ្យសិទ្ធិជាអ្នកប្រើប្រាស់ដល់ក្រុមអ្នកប្រើប្រាស់មានសមត្ថភាព។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទទួលខុសត្រូវដល់ទីបំផុត តាមរយៈនាយកដ្ឋានជលផលសម្រាប់ព្រៃលិចទឹក ព្រៃកោងកាង និងនាយកដ្ឋានរុក្ខាប្រមាញ់ នាពេលពេលបច្ចុប្បន្នជារដ្ឋបាលព្រៃឈើ សម្រាប់ព្រៃទាំងអស់ផ្សេងទៀតនៅក្នុងប្រទេស។ មន្ទីរកសិកម្មខេត្ត គួរមានអំណាចក្នុងការសម្រេចឱ្យសិទ្ធិជាអ្នកប្រើប្រាស់ដោយផ្ទាល់ ដល់ក្រុមអ្នកប្រើប្រាស់ដែលមានសមត្ថភាព។ នាយកដ្ឋានរុក្ខាប្រមាញ់ (រដ្ឋបាលព្រៃឈើ) ត្រូវតែជាអង្គភាពដឹកនាំសហគមន៍ព្រៃឈើក្នុងប្រទេស ជាមួយនឹងការទទួលខុសត្រូវសម្រាប់ការសន្ទនា និងការសម្របសម្រួលអន្តរក្រសួង និងអន្តរនាយកដ្ឋាន ពង្រីកយុទ្ធសាស្ត្រសម្រាប់ដំណើរការសហគមន៍ព្រៃឈើនៅតាមបណ្តាខេត្ត។

3) គួរបង្កើតឱ្យមានបទបញ្ញត្តិ ឬលក្ខខណ្ឌ សម្រាប់ទីភ្នាក់ងារផ្សេងៗឯទៀតទោះជារដ្ឋាភិបាល ឬក្រៅរដ្ឋាភិបាលក្តី សម្រាប់ដើរតួនាទីជាអ្នកផ្តល់ព័ត៌មានក្នុងការទ្រទ្រង់សហគមន៍ក្នុងដំណើរការពង្រីកផែនការគ្រប់គ្រងធនធានព្រៃឈើ និងការអនុវត្តសម្រាប់សិទ្ធិអ្នកប្រើប្រាស់។ វាគួរតែបង្កើតឱ្យច្បាស់ថា ទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀតដូចជា ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល គួរតែត្រូវបានអនុញ្ញាតក្នុងការជួយផ្តល់ជំនួយការដល់សហគមន៍ដូចដែលគេអាចបញ្ចូលជាមួយគ្នានៅក្នុងការអភិវឌ្ឍន៍ជនបទរបស់ទីភ្នាក់ងារទាំងនោះ។

4) ការដោះស្រាយទំនាស់ គួរបង្កើតឱ្យមានអង្គការមួយមានអំណាចក្នុងការធ្វើសេចក្តីសម្រេចដល់កំពូល និងចាត់តាំងទីភ្នាក់ងារផ្សេងដែលអាចដើរតួ រួមចំណែកក្នុងការសម្របសម្រួល ដើម្បីដំណើរការដោះស្រាយទំនាស់ដែលកើតមានទាំងឡាយ។

# ជំពូកទី២
# ស្ថានភាពទូទៅសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

## ២.១. ភូមិសាស្ត្រសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

### ២.១.១. ទីតាំងភូមិសាស្ត្រ

សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន មានទីស្នាក់ការតាំងនៅភូមិព្រៃយ៉ាវ ឃុំស្រែក្នុង ស្រុកជុំគិរី ខេត្តកំពត។ ទីតាំងភូមិសាស្ត្រនៃព្រៃសហគមន៍ គឺស្ថិតនៅតាមបណ្តោយប៉ែកខាងកើតនៃភូមិទាំងបី គឺភូមិព្រៃយ៉ាវ ភូមិត្បែងពក និងភូមិដំណាក់ឈ្នួល ស្ថិតក្នុងឃុំស្រែក្នុង ស្រុកជុំគិរី ខេត្តកំពត ដែលជាខេត្តមួយស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា ជាប់នឹងតំបន់សមុទ្រ។ ទីតាំងព្រៃសហគមន៍ភាគច្រើនស្ថិតនៅលើសណ្ឋានដីតំបន់កូនភ្នំ និងខ្នងទួល ដូចជាភ្នំខ្នងវង់ ជាប់ភូមិដំណាក់ឈ្នួល ភ្នំលាក់ព្រះជាប់ភូមិត្បែងពក ភ្នំដងរ៉ែកជាប់ភូមិព្រៃយ៉ាវ និងខ្នងទួលទ័ពឬស្សី។

សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន មានផ្ទៃដីសរុបចំនួន ៩៨៥ ហិកតា ដែលមានព្រំប្រទល់ៈ

- ខាងជើងជាប់នឹងភូមិព្រៃឃ្លៃ ត្រង់ចំណុចផ្លូវឡើងទៅថ្មស
- ខាងកើតទល់នឹងចំការអូរឆក់ជំនាង
- ខាងត្បូងទល់នឹងផ្លូវរទេះទំនប់តាកុច
- ខាងលិចទល់នឹងដីស្រែអ្នកភូមិ

សហគមន៍ព្រៃឈើនេះ មានទីតាំង២កន្លែងផ្សេងគ្នា មានផ្ទៃដី និងនិយាមកាដូចខាងក្រោម៖

ទីតាំងទី១៖ មានផ្ទៃដី ៨១៨ ហិកតា មាននិយាមកាៈ

| | | |
|---|---|---|
| – ខាងជើង | A(444248_1218142) | B(445882_1218146) |
| – ខាងកើត | B(445882_1218146) | C(446451_1217277) |
| | D(445590_121420) | E (44479_1212072) |
| – ខាងត្បូង | E (44479_1212072) | F (444493_1212693) |
| – ខាងលិច | F (444493_1212693) | A (444248_1218142) |

ទីតាំងទី២ មានផ្ទៃដី ៖ ១៦៧ ហិកតា មាននិយាមកាៈ

| | | |
|---|---|---|
| – ខាងជើង | A (446012_1214653) | B (446389_1214929) |
| – ខាងកើត | B (446389_1214929) | C (446423_1212824) |
| – ខាងត្បូង | C (446423_1212824) | E (445153_1213029) |
| – ខាងលិច | E (445153_1213029) | A (446012_1214653) |

### ២.១.២. ស្ថានភាពដី

ទម្រង់សណ្ឋានដីក្នុងតំបន់នេះបង្កឱ្យមានភាពហូរច្រោះយ៉ាងងាយ បើគ្មានព្រៃឈើ ការហូរច្រោះនឹងកើនឡើងធ្វើឱ្យខូចខាតដល់ដីស្រែចំការទៀតផង[18]។ ប្រភេទដីភាគច្រើនជាល្បាយខ្សាច់ម៉ត់ពណ៌ក្រហម និងកន្លែងខ្លះជាល្បាយគ្រួសក្រហម ឯដីភ្នំសំបូរដោយថ្មក្រៃ។

### ២.១.៣. ផែនទីព្រៃសហគមន៍

**រូបភាពទី៣**

ផែនទីសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន




ប្រភព: ខណ្ឌរដ្ឋបាលព្រៃឈើកំពត

[18] របាយការណ៍សារពើភ័ណ្ឌព្រៃឈើសហគមន៍ដំណាក់អ្នកតាថ្មពូន របស់ក្រុមការងារនៃគម្រោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើនៅកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម, ២០០២។

## ២.២. ទស្សនៈវិស័យ និងបេសកកម្ម

### ២.២.១. ទស្សនៈវិស័យ

សហគមន៍ព្រៃឈើព្រៃឈើដំណាក់អ្នកតាថ្មពូន ចង់ឃើញសមាជិកសហគមន៍ទាំងអស់ស្មោះត្រង់ជាមួយសហគមន៍របស់ខ្លួន មានសាមគ្គីភាពផ្ទៃក្នុងរបស់សហគមន៍ និងចេះជួយគ្នាក្នុងកិច្ចការពារព្រៃឈើសហគមន៍នៅមូលដ្ឋានអោយមាននិរន្តរភាព។

### ២.២.២. បេសកកម្ម

សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន មានបេសកកម្មដូចខាងក្រោម៖

- ចូលរួមអនុវត្តគោលនយោបាយវិស័យព្រៃឈើថ្នាក់ជាតិ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។
- ថែរក្សាព្រៃឈើ សត្វព្រៃ ធនធានរ៉ែ និងប្រភពទឹកដើម្បីជាប្រយោជន៍រួមរបស់ប្រជាជនក្នុងសហគមន៍មូលដ្ឋាន
- លុបបំបាត់ការកាប់បំផ្លាញព្រៃឈើដោយអនាធិបតេយ្យ និងការទន្ទ្រានយកដីព្រៃធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនឯកជន។
- បង្កើនការចូលរួមដោយប្រសិទ្ធិភាពជាអតិបរមាក្នុងការគ្រប់គ្រងអភិរក្ស និងប្រើប្រាស់ព្រៃសហគមន៍ឱ្យមាននិរន្តរភាព និងអភិបាលល្អ។
- អភិវឌ្ឍន៍ព្រៃសហគមន៍ ដើម្បីបង្កើនគំរបព្រៃឈើ តាមរយៈការដាំដើមឈើឡើងវិញ។
- បំពេញតម្រូវការប្រើប្រាស់របស់សហគមន៍ បែងចែកផលប្រយោជន៍ដោយសមធម៌ និងលើកស្ទួយជីវភាពសមាជិកសហគមន៍ព្រៃឈើ។

## ២.៣. ការជ្រើសរើសសមាសភាពគណៈកម្មការគ្រប់គ្រង

យោងលទ្ធផលដែលសិក្សាស្រាវជ្រាវបានបង្ហាញថា អ្នកដឹកនាំក្នុងការងារសហគមន៍ព្រៃឈើ ដែលមានគណៈកម្មការ និងអនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ បានជ្រើសរើសឡើងតាមការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ អ្នករៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវបានជ្រើសរើសចេញពីចាស់ព្រឹទ្ធាចារ្យ ឬគណៈកម្មការអាចារ្យវត្ត ព្រះចៅអធិការវត្ត នាយកកម្រង ប្រធានភូមិ និងក្រុមអ្នកសម្របសម្រួល។ ការជ្រើសរើសសមាសភាពគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវបានបែងចែកដូចខាងក្រោម[19]៖

- ប្រធាន និងអនុប្រធានក្រុម ត្រូវបានបោះឆ្នោតដោយសមាជិកសហគមន៍ក្នុងក្រុមនីមួយៗ
- អនុប្រធានអនុគណៈកម្មការគ្រប់គ្រងសហគន៍ព្រៃឈើក្នុងភូមិនីមួយៗ ត្រូវបានបោះឆ្នោតដោយ

[19] បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២៦ វិច្ឆិកា ២០០៣, ប្រការ៣។

សមាជិកសហគមន៍តាមភូមិនីមួយៗ

- គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវបានបោះឆ្នោតដោយប្រធានអនុប្រធានក្រុមក្នុងភូមិទាំងបី

អ្នកដែលត្រូវឈរឈ្មោះជាអនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើក្នុងភូមិនីមួយៗ ត្រូវបានជ្រើសរើសចេញពីប្រធានក្រុម។ ការជ្រើសរើសនេះ ត្រូវបានសុំយោបល់ និងយល់ព្រមពីសាមីខ្លួនដែរ ។ ចំពោះអ្នកឈរឈ្មោះជាគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវបានជ្រើសរើសចេញពីអនុគណៈកម្មការដែលជាប់ឆ្នោតតាមភូមិនីមួយៗ។ ក្នុងករណីអនុគណៈកម្មការជាប់ឆ្នោតទៅជាគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ អ្នកដែលមានសម្លេងបន្ទាប់ក្នុងពេលបោះឆ្នោតឡើងជាអនុគណៈកម្មការតាមភូមិវិញដោយស្វ័យប្រវត្តិ។ ការជ្រើសរើសគណៈកម្មការសហគមន៍ ត្រូវបានផ្តល់ឱកាស និងលើកទឹកចិត្តឱ្យមានការចូលរួមពីស្ត្រីដែរ[20]។ គ្រួសារជាសមាជិកសហគមន៍ព្រៃឈើត្រូវឱ្យតំណាងម្នាក់នៅក្នុងបន្ទុកគ្រួសារមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ចូលរួមបោះឆ្នោត។ ចំពោះគ្រួសារណាដែលមិនបានចូលរួម ពុំមានសិទ្ធិតវ៉ាលើលទ្ធផលបោះឆ្នោតបានឡើយ។ រយៈពេលនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវបានធ្វើឡើងតែមួយថ្ងៃ។ ការរាប់សន្លឹកឆ្នោត ត្រូវធ្វើឡើងដោយចំហរនៅចំពោះមុខអ្នកចូលរួមបោះឆ្នោតទាំងអស់។ ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវបានអញ្ជើញឱ្យចូលរួមសង្កេតការណ៍ពីប្រធានភូមិ ក្រុមប្រឹក្សាឃុំ និងខណ្ឌរដ្ឋបាលព្រៃឈើ។ អ្នករៀបចំការបោះឆ្នោតធ្វើកំណត់ហេតុស្តីពីលទ្ធផលនៃការបោះឆ្នោត។ កំណត់ហេតុនេះ ត្រូវបានសម្លងជូនខណ្ឌរដ្ឋបាលព្រៃឈើមួយច្បាប់ ក្រុមប្រឹក្សាឃុំមួយច្បាប់ និងតម្កល់ទុកជាឯកសារក្នុងសហគមន៍។ ការប្រកាសលទ្ធផល ត្រូវបានធ្វើឡើងបន្ទាប់ពីរាប់សន្លឹកឆ្នោតរួច។ បេក្ខជនដែលជាប់ឆ្នោតនឹងក្លាយទៅជាអនុគណៈកម្មការ ឬគណៈកម្មការគ្របគ្រងសហគមន៍ព្រៃឈើ ហើយចាប់ផ្តើមដឹកនាំអនុវត្តការងារក្នុងសហគមន៍។

## ២.៤. អាណត្តិរបស់គណៈកម្មការគ្រប់គ្រង

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ មានដូចខាងក្រោម[21]៖

- ប្រធាន ឬអនុប្រធានក្រុមសហគមន៍ព្រៃឈើមានរយៈពេល ៥ឆ្នាំ
- អនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើមានរយៈពេល ៥ឆ្នាំ
- គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើមានរយៈពេល ៥ឆ្នាំ

ក្នុងករណីអសកម្ម ឬលាលែងបញ្ឈប់ពីតំណែងប្រធាន អនុប្រធានក្រុម អនុគណៈកម្មការ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវជ្រើសរើសជំនួសថ្មីដោយយកអ្នកដែលមានសម្លេងបន្ទាប់ក្នុងពេលបោះឆ្នោត

[20] បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២៦ វិច្ឆិកា ២០០៣, ប្រការ៥។

[21] បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២៦ វិច្ឆិកា ២០០៣, ប្រការ ១១។

ឬធ្វើការបោះឆ្នោតជាលក្ខណៈដោយឡែកស្របតាមកម្មវិធីប្រជុំផ្សេងៗ។ ប្រធានក្រុម អនុប្រធាន គណៈកម្មការ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ មានសិទ្ធិឈរឈ្មោះគ្រប់អាណត្តិទៅតាមការស្ម័គ្រចិត្តរបស់សាមីខ្លួន។

## ២.៥. រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រង

**តារាងទី១**

រចនាសម្ព័ន្ធសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន




ប្រភព: ខណ្ឌរដ្ឋបាលព្រៃឈើកំពត

## ២.៦. សមាសភាពគណៈកម្មការគ្រប់គ្រង

យោងតាមដីកាលេខ ៨៩/០៩ដ.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ឃុំស្រែក្នុង របស់ក្រុមប្រឹក្សាឃុំស្រែក្នុងស្រុកជុំគីរី ខេត្តកំពត បានទទួលស្គាល់សមាសភាពគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដូចខាងក្រោម[22]៖

[22] ដីកាស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូនឃុំស្រែក្នុង, លេខ៨៩/០៩ដ.ក, ៣០ មីនា ២០០៩, ប្រការ១។

- គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ មានចំនួន ០៧នាក់ ក្នុងនោះស្រី២នាក់ មានភារកិច្ចទទួលខុសត្រូវរួមទាំង ៣ភូមិ ដែលមានភូមិព្រៃយ៉ាវ ភូមិត្បែងពក និងភូមិដំណាក់ឈ្នួល។
- អនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើតាមភូមិនីមួយៗ មានចំនួន ៥នាក់ មានភារកិច្ចទទួលខុសត្រូវតាមភូមិរបស់ខ្លួនដោយសហការជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ។
- ក្រុមសហគមន៍ព្រៃឈើ មានប្រធានក្រុម អនុប្រធានក្រុម មានភារកិច្ចទទួលខុសត្រូវក្នុងក្រុម របស់ខ្លួនតាមភូមិ និងទំនាក់ទំនងការងារជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងអនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ។
- អ្នកសម្របសម្រួល មានទីប្រឹក្សា អ្នកទ្រទ្រង់ អ្នកផ្តល់ប្រឹក្សា អ្នកគាំទ្រសហគមន៍ព្រៃឈើ។

**ក. សមាសភាពគណៈកម្មការគ្រប់គ្រងព្រៃសហគមន៍ មាន ៧ រូប (ប្រុស៥រូប ស្រី២រូប)៖**

| | | | |
|---|---|---|---|
| ១. លោក ទេព អាន់ | ជាប្រធាន | ២. លោក ឡុង ប៊ុនស៊ុល | ជាអនុប្រធាន |
| ៣. លោកស្រី ជុំ ចន្ថា | ជាអនុប្រធាន | ៤. លោក សុត ឌឹម | ជាលេខាធិការ |
| ៥. លោក ប៊ុន ឈន | ជាហិរញ្ញឹក | ៦. លោក គឹម ផែត | ជាសមាជិក |
| ៧. លោកស្រី យុន សារុន | ជាសមាជិក | | |

**ខ. សមាសភាពអនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ភូមិព្រៃយ៉ាវ មាន ៥ រូប (ប្រុស៤ ស្រី១)**

| | | | |
|---|---|---|---|
| ១. លោក គឹម កប | ជាប្រធាន | ២.លោក រស់ សំបូរ | ជាអនុប្រធាន |
| ៣. លោក ហ៊ួត យាង | ជាអនុប្រធាន | ៤. លោក សាក់ កុល | ជាលេខាធិការ |
| ៥. លោកស្រី ឱញ ភា | ជាហិរញ្ញឹក | | |

**គ. សមាសភាពអនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ភូមិត្បែងពក មាន ៥រូប (ប្រុស៤ ស្រី១)**

| | | | |
|---|---|---|---|
| ១. លោក ញ៉ាញ់ ទង | ជាប្រធាន | ២. លោក ឡុង ឡេន | ជាអនុប្រធាន |
| ៣. លោក សៅ វ៉ាង | ជាអនុប្រធាន | ៤. លោក វ៉ែន និត | ជាហិរញ្ញឹក |
| ៥. លោកស្រី អែម គៀម | ជាលេខាធិការ | | |

**ឃ. សមាសភាពអនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ភូមិដំណាក់ឈ្នួល មាន ៥ រូប (ប្រុស៤ រូប ស្រី១រូប)**

| | | | |
|---|---|---|---|
| ១. លោក ទិន យាន | ជាប្រធាន | ២. លោក មុំ តាំ | ជាអនុប្រធាន |
| ៣. លោក សៅ វឌ្ឍនៈ | ជាអនុប្រធាន | ៤. លោក លី ចក់ | ជាលេខាធិការ |
| ៥. លោកស្រី ទី កល្យាណ | ជាហិរញ្ញឹក | | |

## ២.៧. ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មការ និងអនុគណៈកម្មការគ្រប់គ្រង

### ២.៧.១. ភារកិច្ច

ភារកិច្ចរបស់គណៈកម្មការគ្រប់គ្រង និងអនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ[23]៖

- រៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់គ.កគ្រប់គ្រងសហគមន៍ព្រៃឈើ
- រៀបចំ និងអនុវត្តន៍លក្ខន្តិកៈសហគមន៍ព្រៃឈើដោយមានការចូលរួមពីស្ថាប័នជំនាញពាក់ព័ន្ធ
- រៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងសហគមន៍ និងផែនការគ្រប់គ្រងព្រៃសហគមន៍ ដោយមានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ។
- អនុវត្តតាមលក្ខខណ្ឌបទបញ្ជាផ្ទៃក្នុងរបស់គ.កគ្រប់គ្រងសហគមន៍ព្រៃឈើ លក្ខន្តិកៈសហគមន៍ កិច្ចព្រមព្រៀងសហគមន៍ ផែនការគ្រប់គ្រងសហគមន៍ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ។
- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ
- ធ្វើការសម្រុះសម្រួល និងដោះស្រាយទំនាស់ដែលកើតមាន
- គ្រប់គ្រងហិរញ្ញវត្ថុសហគមន៍ព្រៃឈើឱ្យមានតម្លាភាព និងការទទួលខុសត្រូវ
- ធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍសហគមន៍ព្រៃឈើដោយយល់ព្រមពីសមាជិកសហគមន៍ព្រៃឈើ
- រាយការណ៍ផ្តល់ពត៌មានជាបន្ទាន់នូវរាល់បទល្មើសព្រៃឈើ ក្នុងតំបន់ព្រៃសហគមន៍ដល់រដ្ឋបាលព្រៃឈើដែលនៅជិតបំផុត។
- ផ្តល់ពត៌មានដល់សមាជិកសហគមន៍ព្រៃឈើ
- ធ្វើរបាយការណ៍ជាប្រចាំអំពីដំណើរការសហគមន៍ព្រៃឈើជូនខណ្ឌរដ្ឋបាលព្រៃឈើកំពត ស្របតាមការកំណត់ក្នុងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

### ២.៧.២. ការទទួលខុសត្រូវ

#### ២.៧.២.១. ការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រង

ការទទួលខុសត្រូវនៃគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន[24]៖

**ក. ប្រធាន**

- ដឹកនាំការងាររួមរបស់សហគមន៍ព្រៃឈើ។
- សម្របសម្រួលការងារជាមួយស្ថាប័នជំនាញ ដើម្បីគាំទ្រដល់ការងារសហគមន៍ព្រៃឈើ
- ទំនាក់ទំនងជាមួយអង្គការនានាដើម្បីស្វែងរកជំនួយទ្រទ្រង់សកម្មភាពសហគមន៍។

[23] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២០០៩, ប្រការ១៧។
[24] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២០០៩, ប្រការ១៨។

- ពិនិត្យសំណើរបស់ក្រុម ឬ សមាជិកសហគមន៍ព្រៃឈើ។
- សម្របសម្រួលដោះស្រាយបញ្ហាក្នុងសហគមន៍ព្រៃឈើ។
- ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពការងាររួមរបស់សហគមន៍ព្រៃឈើទាំងមូល។
- ត្រូវផ្តល់ភាពយុត្តិធម៌ និងតម្លាភាពដល់សមាជិកសហគមន៍ព្រៃឈើទាំងមូល។

**ខ. អនុប្រធាន**

- ចូលរួមអនុវត្តការងារជាមួយប្រធាន។
- ជំនួសមុខឱ្យប្រធាននៅពេលអវត្តមាន។
- បំពេញភារកិច្ចផ្សេងៗដែលប្រធានប្រគល់ឱ្យ។

**គ. លេខាធិការ**

- កត់ត្រា និងធ្វើរបាយការណ៍។
- ជំនួយការឱ្យប្រធាន និងអនុប្រធានក្នុងកិច្ចការរដ្ឋបាល។
- គ្រប់គ្រងឯកសារសហគមន៍ព្រៃឈើ។

**ឃ. ហិរញ្ញិក**

- ប្រមូល និងគ្រប់គ្រងថវិកាបានពីការបង់ភាគរយក្នុងការដកហូតផល-អនុផលព្រៃឈើសហគមន៍ ដើម្បីទុកការពារព្រៃសហគមន៍ និងជួយអភិវឌ្ឍសហគមន៍ ដូចជាធ្វើផ្លូវភ្លើង ជួយដល់សមាជិកសហគមន៍ព្រៃឈើ និងចំណាយក្នុងការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ជាដើម។
- កត់ត្រានិងធ្វើរបាយការណ៍ពីស្ថានភាពចំណូលចំណាយនៅរៀងរាល់កិច្ចប្រជុំរបស់គ.កគ្រប់គ្រងសហគមន៍ព្រៃឈើ។

**ង. សមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ**

- ចូលរួមសកម្មភាពនិងប្រឹក្សាយោបល់ជាមួយអ្នកដឹកនាំនិងគ្រប់គ្រងសហគមន៍ព្រៃឈើ
- ជំនួយការ និងជំនួសប្រធាន អនុប្រធាន។

### ២.៧.២.២. ការទទួលខុសត្រូវអនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ

ការទទួលខុសត្រូវរបស់អនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន[25]៖

**ក. ប្រធាន**

- ដឹកនាំការងារសហគមន៍ព្រៃឈើក្នុងភូមិ។
- សម្របសម្រួលការងារជាមួយស្ថាប័នជំនាញ ដើម្បីគាំទ្រដល់ការងារសហគមន៍ព្រៃឈើ

[25] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២០០៩, ប្រការ១៩។

- ពិនិត្យសំណើរបស់ក្រុម ឬ សមាជិកសហគមន៍ព្រៃឈើ។
- សម្របសម្រួលដោះស្រាយបញ្ហាក្នុងសហគមន៍ព្រៃឈើ។

**ខ. អនុប្រធាន**

- ចូលរួមអនុវត្តការងារជាមួយប្រធានអនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ
- ជំនួសមុខឱ្យប្រធាននៅពេលអវត្តមាន។
- បំពេញភារកិច្ចផ្សេងៗដែលប្រធានប្រគល់ឱ្យ។

**គ. លេខាធិការ**

- កត់ត្រា និង ធ្វើរបាយការណ៍។
- ជំនួយការឱ្យប្រធាន និងអនុប្រធានក្នុងកិច្ចការរដ្ឋបាល។
- គ្រប់គ្រងឯកសារសហគមន៍ព្រៃឈើក្នុងភូមិរបស់ខ្លួន។

**ឃ. ហិរញ្ញឹក**

- ប្រមូលនិងគ្រប់គ្រងប្រាក់ភាគទានដែលបានពីសមាជិកសហគមន៍ព្រៃឈើក្នុងភូមិសម្រាប់ក្រុមយាមល្បាតព្រៃសហគមន៍។
- ធ្វើរបាយការណ៍ និងរាយការណ៍ពីចំនួនប្រាក់ចំណូល ចំណាយនៅរៀងរាល់កិច្ចប្រជុំរបស់ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ។

# ជំពូកទី៣

# ដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

## ៣.១. ដំណើរការនៃការរៀបចំបង្កើតសហគមន៍ព្រៃឈើ

ដំណើរការរៀបចំបង្កើត និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងព្រៃឈើសហគមន៍ ចាំបាច់ត្រូវអនុវត្តតាម ៨ ជំហាន ដែលមានដូចខាងក្រោម[26]៖

- **ជំហានទី១៖ ការចាប់ផ្តើមរៀបចំសហគមន៍ព្រៃឈើ**

ដំណើរការរៀបចំបង្កើតសហគមន៍ព្រៃឈើ ចាំបាច់ត្រូវសិក្សាស្វែងយល់ពីសហគមន៍មូលដ្ឋាន ដែលត្រូវធ្វើការផ្សព្វផ្សាយអំពីផលប្រយោជន៍សហគមន៍ព្រៃឈើ ការរៀបចំបែបបទស្នើសុំបង្កើតសហគមន៍ព្រៃឈើទៅអភិបាលខេត្ត។ ការសិក្សាតម្រូវការ និងបញ្ហាជួបប្រទះរបស់សហគមន៍មូលដ្ឋាន។ ការរៀបចំនេះតម្រូវឱ្យមានក្រុមការងារចូលរួមពីរដ្ឋបាលព្រៃឈើ មន្ទីរកសិកម្មខេត្ត ខណ្ឌរដ្ឋបាលព្រៃឈើ ផ្នែករដ្ឋបាលព្រៃឈើ សង្កាត់រដ្ឋបាលព្រៃឈើ ក្រុមប្រឹក្សាឃុំសង្កាត់ ដៃគូអភិវឌ្ឍន៍ ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

- **ជំហានទី២៖ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ព្រៃឈើ**

ការរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដោយមានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ និងការរៀបចំពាក្យស្នើសុំផ្ទៃដីព្រៃសហគមន៍ទៅខណ្ឌរដ្ឋបាលព្រៃឈើ។

- **ជំហានទី៣៖ ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ**

ការរៀបចំរបៀបរបបការងារ និងវិន័យផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដោយមានការបញ្ជាក់ និងឯកភាពពីមេឃុំ និងត្រូវធ្វើការផ្សព្វផ្សាយដល់សមាជិកសហគមន៍ព្រៃឈើ ដើម្បីចូលរួមអនុវត្ត។

- **ជំហានទី៤៖ ការរៀបចំព្រំប្រទល់ព្រៃសហគមន៍**

ការរៀបចំកំណត់ព្រំប្រទល់ព្រៃសហគមន៍នៅលើទីវាល ដោយប្រើប្រាស់ឧបករណ៍ជីភីអេស (GPS) និងសំណាកធម្មជាតិដោយមានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ អ្នកពាក់ព័ន្ធ និងខណ្ឌរដ្ឋបាលព្រៃឈើ។

- **ជំហានទី៥៖ ការរៀបចំលក្ខន្តិកៈសហគមន៍ព្រៃឈើ**

ការរៀបចំបទដ្ឋានក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងមានការបញ្ជាក់ឯកភាពពីមេឃុំ និងត្រូវធ្វើការផ្សព្វផ្សាយដល់សមាជិកសហគមន៍ព្រៃឈើដើម្បីចូលរួមអនុវត្ត។

- **ជំហានទី៦៖ ការរៀបចំកិច្ចព្រមព្រៀងព្រៃសហគមន៍**

ការរៀបចំកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ រវាងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ជាមួយខណ្ឌរដ្ឋបាលព្រៃឈើ ដើម្បីធានាដល់ការគ្រប់គ្រងព្រៃសហគមន៍មានប្រសិទ្ធភាព។

---

[26] ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, លេខ២១៩ប្រក.កសក, ២០០៦។

❖ **ជំហានទី៧៖ ការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ និងការអភិវឌ្ឍ**

ការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ដើម្បីអភិវឌ្ឍ និងប្រើប្រាស់ប្រកបដោយចីរភាព ដោយមានការបញ្ជាក់ឯកភាពពីខណ្ឌរដ្ឋបាលព្រៃឈើ និងត្រូវធ្វើការផ្សព្វផ្សាយដល់សមាជិកសហគមន៍ព្រៃឈើដើម្បីអនុវត្ត។

❖ **ជំហានទី៨៖ ការត្រួតពិនិត្យ និងវាយតម្លៃ**

ការត្រួតពិនិត្យ និងវាយតម្លៃទៅលើសកម្មភាពអនុវត្ត និងគ្រប់គ្រងព្រៃសហគមន៍ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ។

## ៣.២. ការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍

ដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ និងការប្រើប្រាស់ធនធានធម្មជាតិព្រៃឈើសហគមន៍ ក៏អនុវត្តទៅតាម ៨ ជំហានដែរ ដែលមានដូចខាងក្រោម៖

- ❖ ជំហានទី១៖ ការប្រជុំរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍
- ❖ ជំហានទី២៖ ការបែងចែកព្រៃសហគមន៍ជាប្លុកនៅលើផែនទី
- ❖ ជំហានទី៣៖ ការអង្កេតផ្ទៀងផ្ទាត់ព្រៃសហគមន៍តាមប្លុក
- ❖ ជំហានទី៤៖ ការចុះកំណត់ព្រៃសហគមន៍ជាប្លុក
- ❖ ជំហានទី៥៖ ការធ្វើសារពើភ័ណ្ឌព្រៃសហគមន៍ជាប្លុក
- ❖ ជំហានទី៦៖ ការបង្ហាញលទ្ធផលសារពើភ័ណ្ឌព្រៃសហគមន៍
- ❖ ជំហានទី៧៖ ការសរសេរផែនការគ្រប់គ្រងព្រៃសហគមន៍
- ❖ ជំហានទី៨៖ ការដាក់ជូនខណ្ឌរដ្ឋបាលព្រៃឈើពិនិត្យ និងសំរេច

## ៣.៣. កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ បានរៀបចំកិច្ចប្រជុំទៀងទាត់តាមផែនការ ដែលកិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ អាចចែកចេញជាពីរប្រភេទគឺ កិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ។ កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវធ្វើឡើងស្របទៅតាមប្រការទី១៩ នៃលក្ខន្តិកៈសហគមន៍ព្រៃឈើ តាមឋានានុក្រមដូចខាងក្រោម[27]៖

### ៣.៣.១. កិច្ចប្រជុំសាមញ្ញ

**ក. ប្រធានក្រុម** ត្រូវប្រជុំរៀងរាល់ត្រូវចូលរួមប្រជុំរៀងរាល់២ខែម្តង ក្រោមការដឹកនាំប្រជុំដោយអនុគណៈកម្មការគ្រប់គ្របសហគមន៍ព្រៃឈើតាមភូមិនីមួយៗដោយកំណត់យកថ្ងៃទី២៥ វេលាម៉ោង១១:00-២:00 រសៀល រីឯកន្លែងប្រជុំត្រូវអនុវត្តទៅតាមការកំណត់របស់ដឹកនាំអង្គប្រជុំ។

[27] បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២៦ វិច្ឆិកា ២០០៣, ប្រការ១៤។

**តារាងទី២**

ផែនការប្រជុំរបស់ប្រធានក្រុម

| ថ្ងៃ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ម៉ោង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សុក្រ | ២៥ | | | | | | | | | | | | ១១:០០ |
| ច័ន្ទ | | | ២៥ | | | | | | | | | | ១១:០០ |
| សៅរ៍ | | | | | ២៥ | | | | | | | | ១១:០០ |
| ព្រហ | | | | | | | ២៥ | | | | | | ១១:០០ |
| ពុធ | | | | | | | | | ២៥ | | | | ១១:០០ |
| ច័ន្ទ | | | | | | | | | | | ២៥ | | ១១:០០ |

ប្រភព: សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

**ខ. អនុគណៈកម្មការ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ** ត្រូវប្រជុំរៀងរាល់មួយខែម្តង ក្រោមការដឹកនាំប្រជុំដោយប្រធានគណៈកម្មការសហគមន៍ព្រៃឈើ។ ដោយកំណត់យករាល់ថ្ងៃទី៣០ នៅវេលាម៉ោង១ ដល់ម៉ោង៤រសៀល ទីកន្លែងប្រជុំត្រូវកំណត់ទៅតាមការវិលជុំរបស់ភូមិទាំងបី។

**តារាងទី៣**

ផែនការប្រជុំរបស់គណៈ-អនុកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ

| ថ្ងៃ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ម៉ោង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ពុធ | ៣០ | | | | | | | | | | | | ១:០០ |
| ព្រ.ហ | | ២៨ | | | | | | | | | | | ១:០០ |
| សៅរ៍ | | | ៣០ | | | | | | | | | | ១:០០ |
| អង្គារ៍ | | | | ៣០ | | | | | | | | | ១:០០ |
| ព្រ.ហ | | | | | ៣០ | | | | | | | | ១:០០ |
| អាទិត្យ | | | | | | ៣០ | | | | | | | ១:០០ |
| ព្រ.ហ | | | | | | | ៣០ | | | | | | ១:០០ |
| សុក្រ | | | | | | | | ៣០ | | | | | ១:០០ |
| ច័ន្ទ | | | | | | | | | ៣០ | | | | ១:០០ |
| ពុធ | | | | | | | | | | ៣០ | | | ១:០០ |
| សៅរ៍ | | | | | | | | | | | ៣០ | | ១:០០ |
| ច័ន្ទ | | | | | | | | | | | | ៣០ | ១:០០ |

ប្រភព: សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

**គ.** សមាជិកសហគមន៍ព្រៃឈើទាំងអស់ត្រូវប្រជុំ២ដងក្នុងមួយឆ្នាំ លើកទី១៖ ប្រជុំសមាជិកតាមភូមិក្នុងខែតុលា។ លើកទី២៖ ប្រជុំរួមសមាជិកទាំងបីភូមោក្នុងខែឧសភា ក្រោមការដឹកនាំប្រជុំដោយប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ។

**តារាងទី៤**

ផែនការប្រជុំរបស់សមាជិកសហគមន៍ព្រៃឈើ

| ថ្ងៃ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆកា | ធ្នូ | ម៉ោង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សៅរ៍ | | | | | ប្រជុំលើកទី១ | | | | | | | | ៨:00 |
| សុក្រ | | | | | | | | | | ប្រជុំលើកទី១ | | | ៨:00 |

ប្រភពៈ សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន

### ៣.៣.២. កិច្ចប្រជុំវិសាមញ្ញ

ក្នុងករណីពិសេសអនុគណៈកម្មការ និងគណៈកម្មាគ្រប់គ្រងសហគមន៍ព្រៃឈើ អាចរៀបចំកិច្ចប្រជុំវិសាមញ្ញបានដោយគ្មានកំណត់កាលបរិច្ឆេទច្បាស់លាស់ទេ។ ប្រសិនបើមានការប្រជុំពិសេស ការប្រជុំប្រចាំខែត្រូវបានលើកលែង[28]។ រាល់កិច្ចប្រជុំដែលបានរៀបរាប់ខាងលើ ត្រូវមានលិខិតអញ្ជើញ ក្នុងនោះប្រធានក្រុម និងអនុប្រធានក្រុម ចេញលិខិតអញ្ជើញដោយអនុគណៈកម្មការសហគមន៍ព្រៃឈើ។ អនុគណៈកម្មការ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវចេញលិខិតអញ្ជើញដោយប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ចំពោះការប្រជុំសមាជិកសហគមន៍ព្រៃឈើ ត្រូវមានការអញ្ជើញដោយប្រធានក្រុម ឬអនុប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ។ ការផ្តល់លិខិតអញ្ជើញដល់អ្នកដែលត្រូវចូលរួមឱ្យបាន២ថ្ងៃមុនកិច្ចប្រជុំ។ ក្នុងករណីប្រជុំសមាជិកសហគមន៍ ប្រធានក្រុមអាចអញ្ជើញដោយផ្ទាល់មាត់ឱ្យបាន១ថ្ងៃមុនកិច្ចប្រជុំ។ នៅក្នុងលិខិតអញ្ជើញ ត្រូវបញ្ជាក់ពីគោលបំណងនៃកិច្ចប្រជុំ ទីកន្លែង ពេលវេលា ថ្ងៃខែឆ្នាំ និងរបៀបវារៈនៃកិច្ចប្រជុំ។ ការកំណត់របៀបវារៈនៃកិច្ចប្រជុំ បានផ្តោតសំខាន់ទៅលើសកម្មភាពសហគមន៍ព្រៃឈើ ដែលរួមមាន[29]៖

- ពិនិត្យពីសកម្មភាពដែលបានអនុវត្តកន្លងមក
- អនុម័តលើការចាយវាយថវិកា
- ពិភាក្សា និងអនុម័តទៅលើសំណើការប្រើប្រាស់ផល-អនុផលព្រៃឈើ ដែលសំខាន់ៗរបស់សមាជិកសហគមន៍ព្រៃឈើ
- ដោះស្រាយបញ្ហាផ្សេងដែលកើតមានឡើង
- ពិភាក្សា និងអនុម័តទិសដៅអនុវត្តបន្ត។

[28] បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២៦ វិច្ឆិកា ២០០៣, ប្រការ១៥។

[29] បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២៦ វិច្ឆិកា ២០០៣, ប្រការ២០។

### ៣.៣.៣. របៀបរបបប្រជុំ

នៅក្នុងគ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដែលអាចប្រព្រឹត្តិឡើងបានលុះត្រាតែមានសមាជិកចូលរួមដូចខាងក្រោម[30]៖

– ចំពោះកិច្ចប្រជុំសមាជិករួមរបស់សហគមន៍ ត្រូវមានអ្នកចូលរួមលើសពី៥០ភាគរយ
– ចំពោះកិច្ចប្រជុំប្រធានក្រុម អនុគណៈកម្មការ និងគណៈកម្មការសហគមន៍ ត្រូវមានសមាជិកចាប់ពី៧០ ភាគរយឡើងទៅ។

សមាជិកដែលបានចូលរួមក្នុងកិច្ចប្រជុំ មានសិទ្ធិបញ្ចេញយោបល់ និងចូលរួមសម្រេចចិត្តនានាបាន។ អនុគណៈកម្មការ និងគណៈកម្មការព្រៃឈើ អាចចាត់ឱ្យមានកិច្ចប្រជុំជាសំងាត់បាន ដោយកិច្ចកិច្ចប្រជុំជាសំងាត់នោះគឺធ្វើការពិភាក្សាលើ៖

– ការដោះស្រាយបញ្ហាដែលពាក់ព័ន្ធ ទៅនឹងកិត្តិយសបុគ្គល
– ការរៀបចំចុះទប់ស្កាត់បទល្មើសនានា

កិច្ចប្រជុំទាំងអស់ ត្រូវមានការអញ្ជើញឱ្យមានការចូលរួមពីគណៈកម្មការសម្របសម្រួល និងគណៈកម្មការ ការអភិវឌ្ឍភូមិ។

### ៣.៣.៤. កំណត់ហេតុនៃអង្គប្រជុំ

អ្នកធ្វើកំណត់ហេតុ និងបញ្ជីវត្តមានត្រូវជ្រើសរើសតាំងឡើងដោយប្រធានអង្គប្រជុំ។ កំណត់ហេតុនៃកិច្ចប្រជុំត្រូវកត់ត្រាបញ្ជាក់ពីចំណុចសំខាន់ៗដូចខាងក្រោម[31]៖

– ថ្ងៃ ខែ ឆ្នាំ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំ
– សមាសភាពអ្នកចូលរួម
– របៀបវារៈ
– លទ្ធផលនៃកិច្ចប្រជុំ
– បញ្ហាផ្សេងៗ
– ពេលវេលានៃការបញ្ចប់កិច្ចប្រជុំ។

អ្នកដឹកនាំកិច្ចប្រជុំ ត្រូវចុះហត្ថលេខាទទួលស្គាល់លើកំណត់ហេតុប្រជុំ។ លេខាធិការសហគមន៍ព្រៃឈើជាអ្នករក្សាទុកនូវកំណត់ហេតុ និងឯកសារសេចក្ដីសម្រេចផ្សេងៗក្នុងសហគមន៍។ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវធ្វើរបាយការណ៍ និងចំលងជូនកំណត់ហេតុនៃកិច្ចប្រជុំជូនដល់ក្រុមប្រឹក្សាឃុំ-សង្កាត់។

---

[30] បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២៦ វិច្ឆិកា ២០០៣, ប្រការ២១។

[31] បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២៦ វិច្ឆិកា ២០០៣, ប្រការ៣៧។

## ៣.៤. ការប្រើប្រាស់ធនធានព្រៃឈើសហគមន៍

### ៣.៤.១. ការប្រើប្រាស់ធនធានព្រៃឈើដោយសមាជិកសហគមន៍ព្រៃឈើ

ប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើបានកំណត់ទីតាំង និងបរិមាណផល-អនុផលព្រៃឈើដែលអាចដកហូតដើម្បីប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សមាជិកសហគមន៍ព្រៃឈើ ដោយផ្អែកតាមលទ្ធភាពផ្តល់ផលប្រកបដោយនិរន្តរភាពកំណត់ក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍ និងស្របតាមច្បាប់ស្តីពីព្រៃឈើ។ ការដកហូតឈើបង្គោលរបង ឈើចំរឹង សសរផ្ទះពីព្រៃសហគមន៍ ដោយសមាជិកសហគមន៍ព្រៃឈើ សម្រាប់ប្រើប្រាស់ជាលក្ខណៈប្រពៃណីក្នុងគ្រួសារ ត្រូវបំពេញលើពាក្យស្នើសុំតាមរយៈប្រធានក្រុម អនុគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើប្រចាំភូមិដែលសមាជិកនោះរស់នៅ ហើយបញ្ជូនទៅប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដើម្បីពិនិត្យនិងសម្រេច។ ចំពោះឈើដែលមានអង្កត់ផ្ចិតចាប់ពី១០ស.មឡើងទៅត្រូវបង់ប្រាក់ចំនួន ២០% និងឈើដែលមានអង្កត់ផ្ចិតក្រោម១០ស.ម ត្រូវបង់ប្រាក់ចំនួន ១០% នៃថ្លៃឈើដែលលក់នៅទីផ្សារក្នុងស្រុក [32] ។ ការរុករកផល-អនុផលព្រៃឈើក្នុងសហគមន៍សម្រាប់ប្រើប្រាស់ជាលក្ខណៈប្រពៃណីមិនចាំបាច់ជូនដំណឹង ឬស្នើសុំពីអ្នកដឹកនាំ និងអ្នកគ្រប់គ្រងសហគមន៍ព្រៃឈើឡើយ។

### ៣.៤.២. ការប្រើប្រាស់ធនធានព្រៃឈើក្រៅពីសមាជិកសហគមន៍ព្រៃឈើ

អ្នកប្រើប្រាស់ព្រៃឈើសហគមន៍ មិនមែនជាសមាជិកសហគមន៍ព្រៃឈើស្ថិតនៅក្នុងភូមិជាមួយ មានសិទ្ធិប្រមូលផល-អនុផលព្រៃឈើក្នុងព្រៃសហគមន៍សម្រាប់ប្រើប្រាស់ជាលក្ខណៈប្រពៃណី ត្រូវមានការយល់ព្រមជាមុនពីគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ[33]។ អ្នកមិនមែនជាសមាជិកសហគមន៍ព្រៃឈើ ហើយមកពីភូមិខាងក្រៅមិនមានសិទ្ធិ ឬគ្មានបុព្វសិទ្ធិក្នុងការប្រមូលផល-អនុផលព្រៃឈើក្នុងព្រៃសហគមន៍ឡើយ។ ក្នុងករណីចូលមកប្រមូលផល-អនុផលព្រៃឈើក្នុងព្រៃសហគមន៍នោះ ចាត់ទុកជាអំពើបទល្មើសច្បាប់ ទោះបីការប្រមូលនោះក្នុងរូបភាពជាលក្ខណៈប្រពៃណីក៏ដោយ។

### ៣.៤.៣. ការបែងចែកផលប្រយោជន៍ក្នុងសហគមន៍

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវប្រជុំលើកពីគោលការណ៍ក្នុងការបែងចែកផលប្រយោជន៍សម្រាប់បេឡាអភិវឌ្ឍន៍សហគមន៍ព្រៃឈើផ្ទាល់ និងសម្រាប់សមាជិកសហគមន៍ព្រៃឈើរបស់ខ្លួនដោយឈរលើគោលការណ៍ "**សមធម៌**" និង "**តម្លាភាព**"។ គោលការណ៍បែងចែកផលប្រយោជន៍សហគមន៍ព្រៃឈើ ត្រូវមានការឯកភាពក្នុងសម័យប្រជុំប្រចាំខែ ប្រចាំឆ្នាំរបស់សហគមន៍ព្រៃឈើក្នុងសម្លេងឯកភាពពីរភាគបី[34]។ថវិកាដែលបានមកពីការលក់ផល-អនុផលព្រៃឈើលើសពីសិទ្ធិប្រពៃណី ក្រោមរូបភាពរួមរបស់សហគមន៍ព្រៃឈើ

[32] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួន, ២០០៩, ប្រការ២៥។

[33] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួន, ២០០៩, ប្រការ៣៨។

[34] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួន, ២០០៩, ប្រការ៣៦។

បន្ទាប់ពីបានទូទាត់ចំណាយលើការប្រមូលផល និងបង់ថ្លៃសួយសារ បុព្វលាភជូនរដ្ឋរួចហើយ ត្រូវរក្សាទុកចំនួន ៣៥% (សាមសិបប្រាំភាគរយ) ដើម្បីបង់ចូលបេឡាអភិវឌ្ឍន៍សហគមន៍ព្រៃឈើ។ ដោយឡែកថវិកាចំនួន ៦៥% ទៀត សម្រាប់បែងចែកទៅសមាជិកសហគមន៍ព្រៃឈើ។

### ៣.៤.៤. ការបណ្តុះបណ្តាលសមាជិកសហគមន៍

លោកប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍បានឱ្យដឹងថា គណៈកម្មការគ្រប់សហគមន៍មានផែនការបណ្តុះបណ្តាលដល់សមាជិកសហគមន៍រៀងរាល់៤ខែម្តង ដោយធ្វើទំនាក់ទំនងជាមួយអ្នកជំនាញនានា ដូចជារដ្ឋបាលព្រៃឈើ មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទ មន្ទីរបរិស្ថាន និងអង្គការដៃគូដែលពាក់ធ្វើការផ្តោតទៅលើវិស័យព្រៃឈើ ដោយផ្តោតទៅលើប្រធានបទសំខាន់ៗមួយចំនួន៖

- ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធនឹងបទល្មើសព្រៃឈើ
- ការពង្រឹងសមត្ថភាពពីរបៀបចុះល្បាតព្រៃឈើ
- ជំនាញបណ្តុះកូនឈើនិងដាំកូនឈើ ទំនាក់ទំនង ការគ្រប់គ្រង ភាពជាអ្នកដឹកនាំ របៀបធ្វើផែនការ សរសេររបាយការណ៍ ការស្នើសុំថវិកាទ្រទ្រង់សហគមន៍ព្រៃឈើ
- របៀបសរសេរកិច្ចសន្យាលើបទល្មើសព្រៃឈើ
- របៀបប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម (Facebook) ជាដើម។

### ៣.៤.៥. ការលើកទឹកចិត្តដល់សមាជិកសហគមន៍ព្រៃឈើ

រៀងរាល់ដំណាច់ឆ្នាំនីមួយៗ ប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ តែងធ្វើការផ្តល់រង្វាន់លើកទឹកចិត្តដល់សមាជិកសហគមន៍ណា ដែលបានសម្រេចលទ្ធផលលេចធ្លោក្នុងកិច្ចការពារព្រៃឈើសហគមន៍។ ចំពោះសមាជិកដែលអាចទទួលរង្វាន់ លើកទឹកចិត្តត្រូវមានលក្ខណៈសម្បត្តិ៖

- បានចូលជាសមាជិកសហគមន៍ព្រៃឈើយ៉ាងតិច១ឆ្នាំ
- ស្នាដៃត្រូវបានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ឬសមាជិកសហគមន៍សរសើរ ឬលទ្ធផលនៃការវាយតម្លៃប្រចាំដោយរួមបញ្ចូលទាំងអ្នកពាក់ព័ន្ធនានាសរសើរ

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើអាចលើកទឹកចិត្តដោយផ្តល់នូវសម្ភារៈមួយចំនួន៖

- ដកហូតកូនឈើក្នុងព្រៃសហគមន៍ធ្វើជាទ្រុងមាន់ ក្រោលគោ ឬសរសរផ្ទះជាដើម
- ថវិកាតាមលទ្ធភាពនៃសហគមន៍ តាមការសម្រេចរបស់គណៈកម្មការគ្រប់គ្រងសហគមន៍
- បញ្ជូនទៅរៀនវគ្គបណ្តុះជំនាញខ្លីៗ ដែលទាក់ទងទៅនឹងការប្រកបរបរកសិកម្ម
- ផ្តល់ប័ណ្ណសរសើរដល់ក្រុមដែលមានស្នាដៃល្អ
- បញ្ជូនទៅទស្សនកិច្ចសិក្សាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។

## ៣.៥. វិធានការការពារសហគមន៍ព្រៃឈើ

### ៣.៥.១. ការហាមឃាត់ក្នុងសហគមន៍ព្រៃឈើ

#### ៣.៥.១.១. ការប្រមូលផល-អនុផលព្រៃឈើ

ការប្រមូលផល-អនុផលព្រៃឈើជាលក្ខណៈប្រពៃណី ឬលើសពីសិទ្ធិប្រពៃណីរបស់សហគមន៍មូលដ្ឋាន ត្រូវអនុលោមតាមការអនុញ្ញាត និងការហាមឃាត់ ដូចមានចែងនៅក្នុងច្បាប់ស្តីពីព្រៃឈើ។ ហាមឃាត់ការប្រមូលផល-អនុផលព្រៃឈើក្នុងព្រៃសហគមន៍ ដែលនាំការគំរាមកំហែងដល់ធនធានព្រៃឈើ ឬធ្វើឱ្យវិនាសដល់ប្រភពពូជ ឬការប្រមូលផលយកសម្រាប់តែបុគ្គល គ្រួសារ ក្រុមរបស់ខ្លួន ដោយរំលោភសិទ្ធិសមាជិកសហគមន៍ព្រៃឈើដទៃទៀត។ គ្មានបុគ្គលណាមានសិទ្ធិផ្តល់លិខិតអនុញ្ញាតប្រមូលផល-អនុផលព្រៃឈើក្នុងដែនព្រៃការពារគ្រប់ប្រភេទនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម ដោយមូលហេតុជាអាទិ៍ លក្ខខណ្ឌអាកាសធាតុមិនអំណោយផលឈើ ចំណីផ្លូវត្រូវសាងសង់ដោយមានការអនុញ្ញាត ឬលក្ខខណ្ឌឧបទ្ទវហេតុផ្សេងទៀត ដែលស្នើឡើងដោយរដ្ឋបាលព្រៃឈើ ការប្រមូលផល-អនុផលព្រៃឈើក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ដូចខាងក្រោម[35]៖

- ប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់ ដែលមិនទាន់ដល់ទំហំអប្បរមា អនុញ្ញាតឱ្យកាប់រំលំ
- ប្រភេទឈើដែលមានដោយកម្រ
- ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី
- ដើមឈើផ្តល់ជ័រមានតម្លៃ។

#### ៣.៥.១.២. ការបង្កើតរោងសន្និធិ សិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ

ហាមឃាត់ការកែច្នៃផល-អនុផលព្រៃឈើ ឬការបង្កើត និងដំណើរការមូលដ្ឋាន ឧស្សាហកម្មឈើ រោងចក្រអារឈើ រោងចក្រកែច្នៃឈើ សិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ និងឡគ្រប់ប្រភេទនៅក្នុងដែនព្រៃបម្រុងទុក អចិន្ត្រៃយ៍។ គ្រប់មូលដ្ឋានកែច្នៃផល-អនុផលព្រៃឈើ និងឡគ្រប់ប្រភេទត្រូវមានទីតាំងស្ថិតនៅចំងាយ៥គីឡូម៉ែត្រយ៉ាងតិចពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍[36]។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចធ្វើការលើកលែងការហាមឃាត់ដែលចែងក្នុងកឋាខ័ណ្ឌទី២ នៃមាត្រា៣០ នៃច្បាប់ស្តីពីព្រៃឈើនេះ នៅក្នុងករណីដែលរដ្ឋបាលព្រៃឈើសិក្សាឃើញថាផលប្រយោជន៍នៃការលើកលែងនេះមិនមានផលប៉ះពាល់សង្គមបរិស្ថាន ឬមានផលប៉ះពាល់កម្រិតទាប។

[35] ច្បាប់ស្តីពីព្រៃឈើ, លេខ នស/រកម/០៨០២/០១៦. ៣០ កក្កដា ២០០២, មាត្រា២៩។

[36] ច្បាប់ស្តីពីព្រៃឈើ, លេខ នស/រកម/០៨០២/០១៦. ៣០ កក្កដា ២០០២, មាត្រា៣០។

**៣.៥.១.៣. ការឈូសឆាយស្ថាបនាផ្លូវសាធារណៈ**

ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូនដោយមានការពិគ្រោះយោបល់ជាមួយក្រសួងកសិកម្ម។ រាល់គម្រោងស្ថាបនាផ្លូវសាធារណៈ ផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី ជាមួយនឹងសហគមន៍មូលដ្ឋាន និងការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម តាមមាត្រា៤នៃច្បាប់ស្តីពីព្រៃឈើ។

**៣.៥.១.៤. សកម្មភាពផ្សេងៗ**

ព្រៃឈើត្រូវបានការពារប្រឆាំងនឹងរាល់សកម្មភាពធ្វើឱ្យខូចខាត បណ្តាលមកពីការធ្វើអាជីវកម្មហួសហេតុ ការកាប់រានដីព្រៃដោយរំលោភ ការបំពុលមជ្ឈដ្ឋានព្រៃឈើ ភ្លើងឆេះព្រៃ ការធ្វើចំការពនេចរ ជម្ងឺ សត្វល្អិតចង្រៃ សត្វរាតត្បាត និងការនាំចូលប្រភេទរុក្ខជាតិ។ សកម្មភាពដែលនាំឱ្យខូចខាតដល់ព្រៃឈើ ដែលត្រូវបានហាមឃាត់មានដូចជា[37]៖

- រំកិល ដកចេញ ឬបំផ្លាញគោលសីមា ឬសញ្ញាសម្គាល់សម្រាប់កំណត់ដែនព្រៃឈើ
- គ្រៀវ បំពុល កាប់បំផ្លាញ ផ្តួលរំលំដើម ឬគាស់រំលើងគល់ឈើដោយគ្មានការចាំបាច់ខាង បច្ចេកទេស
- ប្រើសិទ្ធិប្រមូលផល អនុផលព្រៃឈើខុសពីសិទ្ធិ ដែលត្រូវបានទទួលស្គាល់ ឬអនុញ្ញាត។
- ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈក្នុងកន្លែងដែលមានកូនឈើដុះថ្មី ក្រោយពេលមានអាជីវកម្ម ឬភ្លើងឆេះព្រៃ ឬក្នុងតំបន់ព្រៃកំពុងតែដាំ ឬទើបដាំ។
- បង្កើតមូលដ្ឋានកែច្នៃវល្លិ ឬអនុផលព្រៃឈើផ្សេងៗ ដែលនាំមកនូវការបំពុលបំផ្លាញមូលដ្ឋានព្រៃឈើ។
- ការដាក់តាំងលំនៅដ្ឋានថ្មីតាមដងផ្លូវសាធារណៈ ឬផ្លូវព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែមានការអនុញ្ញាតពីរាជរដ្ឋាភិបាល[38]។

ដោយឡែកនៅក្នុងលក្ខន្តិកៈរបស់សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន បានចែងពីការហាមឃាត់នៃការប្រើប្រាស់ផល-អនុផលព្រៃឈើសហគមន៍ ដូចដែលមានចែងក្នុងច្បាប់ស្តីពីព្រៃឈើផងដែរ។ ហាមឃាត់ដាច់ខាតនូវសកម្មភាពមួយចំនួនក្នុងដែនព្រៃសហគមន៍ជាអាទិ៍[39]៖

- ការបំផ្លាញជម្រកសត្វព្រៃគ្រប់ប្រភេទ និងការប្រមាញ់សត្វព្រៃ
- ការលក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវ៉ាស់ បែងចែក ខ្ចី បញ្ចាំ ឬផ្ទេរដីព្រៃសហគមន៍ទោះតាមរូបភាពណាក៏ដោយ

---

[37] ច្បាប់ស្តីពីព្រៃឈើ, លេខ នស/រកម/០៨០២/០១៦. ៣០ កក្កដា ២០០២, មាត្រា៣២។

[38] ច្បាប់ស្តីពីព្រៃឈើ, លេខ នស/រកម/០៨០២/០១៦. ៣០ កក្កដា ២០០២, មាត្រា៣១។

[39] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២០០៩, ប្រការ៤៨។

- ការជីករុករករ៉ែផ្សេងៗក្នុងដែនព្រៃសហគមន៍
- ការដុតរុករានព្រៃសហគមន៍ដោយចេតនា ឬអចេតនាការសម្រាប់ធ្វើចំការ ស្រែ និងភូមិករ។

រាល់ការរំលោភ ឬការប្រព្រឹត្តបទល្មើសព្រៃឈើជាក់ស្តែងនៅក្នុងព្រៃសហគមន៍ ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវឃាត់ខ្លួនជនល្មើស និងវត្ថុតាងហើយរាយការណ៍ជាបន្ទាន់ជូនសង្កាត់រដ្ឋបាលព្រៃឈើជុំគីរី ដើម្បីចាត់ការតាមនីតិវិធី។

### ៣.៥.២. ការដោះស្រាយទំនាស់ក្នុងសហគមន៍ព្រៃឈើ

នៅពេលដែលមានវិវាទកើតឡើងរវាងសហគមន៍ព្រៃឈើ និងសមាជិកសហគមន៍ការដោះស្រាយទំនាស់ទូទៅក្នុងការគ្រប់គ្រងព្រៃសហគមន៍ ត្រូវបានអនុលោមតាមវិធានដូចមានចែងក្នុងជំពូកទី៩ នៃប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។ នាយខណ្ឌរដ្ឋបាលព្រៃឈើ និង/ឬ អាជ្ញាធរមូលដ្ឋាន ត្រូវសម្របសម្រួលដោះស្រាយទំនាស់ក្នុងការអនុវត្តការងារគ្រប់គ្រងសហគមន៍ព្រៃឈើតាមសមត្ថកិច្ចរៀងៗខ្លួន។ ការដោះស្រាយទំនាស់ក្នុងសហគមន៍ព្រៃឈើ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋានឈរលើមូលដ្ឋាននៃការគោរពផលប្រយោជន៍ទាំងសងខាង និងផ្អែកតាមមូលដ្ឋានច្បាប់ជាធរមាន[40]។ ករណីមិនអាចសម្របសម្រួលដោះស្រាយទំនាស់បាន នាយខណ្ឌរដ្ឋបាលព្រៃឈើត្រូវធ្វើរបាយការណ៍ជូនប្រធានរដ្ឋបាលព្រៃឈើ ឬក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវបញ្ជូនសំណុំរឿងក្តីទៅតុលាការខេត្តសាមី ដើម្បីដោះស្រាយតាមផ្លូវច្បាប់[41]។

- ចំពោះទំនាស់រវាងសមាជិក និងសមាជិកសហគមន៍ព្រៃឈើនៅក្នុងភូមិឃុំជាមួយគ្នា គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រធានក្រុមសហគមន៍ជាអ្នកសម្របសម្រួល និងធ្វើការដោះស្រាយ។
- ទំនាស់រវាងសមាជិកសហគមន៍ជាមួយនឹងអ្នកប្រើប្រាស់ព្រៃសហគមន៍ក្រៅភូមិ គណៈកម្មការគ្រប់គ្រង និងប្រធានក្រុមសហគមន៍សហការជាមួយមេភូមិ មេឃុំ ដើម្បីធ្វើការសម្រុះសម្រួល និងដោះស្រាយ។
- ទំនាស់រវាងសមាជិកសហគមន៍ព្រៃឈើជាមួយ អ្នកប្រើប្រាស់ព្រៃសហគមន៍មកពីខាងក្រៅមូលដ្ឋានឃុំនោះគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់ដោយ មានការសម្របសម្រួលពីប្រធានភូមិ និងមេឃុំនិងអាជ្ញាធរមូលដ្ឋានរបស់អ្នកប្រើប្រាស់ព្រៃសហគមន៍។
- ទំនាស់រវាងសមាជិកសហគមន៍ព្រៃឈើជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ ព្រៃឈើអជ្ញាធរឃុំ និងសង្កាត់រដ្ឋបាលព្រៃឈើជុំគីរី និងផ្នែករដ្ឋបាលព្រៃឈើឈូក ឬខណ្ឌរដ្ឋបាលព្រៃឈើកំពត អាចធ្វើ

[40] ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, លេខ២១៩ប្រក.កសក, ២១ កក្កដា ២០០៦, ប្រការ៣០។

[41] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២០០៩, ប្រការ៤៣។

ការសម្របសម្រួលដោះស្រាយទំនាស់ជាមួយអាជ្ញាធរឃុំពាក់ព័ន្ធ។

- ទំនាស់រវាងសមាជិកសហគមន៍ព្រៃឈើពីរ ឬច្រើននៅជាប់គ្នា ត្រូវសម្របសម្រួលដោះស្រាយដោយអាជ្ញាធរឃុំ ស្រុក ខេត្តពាក់ព័ន្ធ[42]។

### ៣.៥.៣. ការដាក់ទណ្ឌកម្មចំពោះជនដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន អាចដាក់ទណ្ឌកម្មចំពោះសមាជិកសហគមន៍ព្រៃឈើណាដែលបានប្រព្រឹត្តបទល្មើសលើកទីមួយ ដែលនាំឱ្យហិនហោចដល់ព្រៃសហគមន៍ ដោយធ្វើការអប់រំណែនាំ និងធ្វើកិច្ចសន្យាពីការរាងចា [43] ។ រាល់វត្ថុតាំងជាផល-អនុផលព្រៃឈើដែលជននោះបានប្រព្រឹត្តល្មើស គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ អាចស្នើសុំរដ្ឋបាលព្រៃឈើមូលដ្ឋានសាមី ដើម្បីរក្សាទុកប្រើប្រាស់ជាផលប្រយោជន៍រួមរបស់សហគមន៍មូលដ្ឋាន។ ករណីសមាជិកសហគមន៍ព្រៃឈើណាប្រព្រឹត្តបទល្មើសដែលបានធ្វើការអប់រំរួចហើយ ហើយមិនរាងចោល គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវឃាត់ទុកវត្ថុតាងទាំងអស់ និងឃាត់ខ្លួនជនល្មើស បញ្ជូនជាបន្ទាន់ទៅសង្កាត់រដ្ឋបាលព្រៃឈើជុំគីរី ដើម្បីចាត់វិធានការតាមនីតិវិធី ហើយសមាជិករូបនោះ ត្រូវបណ្តេញចេញពីសមាជិកភាពសហគមន៍ព្រៃឈើ។

ដោយឡែកចំពោះសមាជិកសហគមន៍ព្រៃឈើណាដែលប្រព្រឹត្តបទល្មើសព្រៃឈើ លើសពីទំហំប្រើប្រាស់ជាលក្ខណៈប្រពៃណី ឬល្មើសនឹងបទប្បញ្ញត្តិហាមឃាត់ដូចមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ ត្រូវទទួលទណ្ឌកម្មអនុលោមតាមទោសប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ។ ចំពោះជនណាដែលមិនមែនជាសមាជិកសហគមន៍ ឬមកពីក្រៅសហគមន៍មូលដ្ឋាន ដែលបានប្រព្រឹត្តបទល្មើសព្រៃឈើក្នុងព្រៃសហគមន៍ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវឃាត់ខ្លួន និងបញ្ជូនជនល្មើសព្រមទាំងវត្ថុតាងជាបន្ទាន់ទៅសង្កាត់រដ្ឋបាលព្រៃឈើជុំគីរី ដើម្បីចាត់វិធានការតាមនីតិវិធី។ បើមានសមាជិកណាសហគមន៍ព្រៃឈើណាដែលឃុបឃិត ឬសមគំនិតជាមួយជន ដែលមកពីក្រៅសហគមន៍មូលដ្ឋានបង្កឱ្យមានបទល្មើសព្រៃឈើក្នុងព្រៃសហគមន៍នោះ និងជនពាក់ព័ន្ធត្រូវទទួលទណ្ឌកម្មតាមប្រភេទបទល្មើសដែលខ្លួនបានប្រព្រឹត្តអនុលោមតាមទោសប្បញ្ញត្តិ ដូចមានចែងនៅក្នុងច្បាប់ស្តីពីព្រៃឈើ។ សមាជិកសហគមន៍ព្រៃឈើ អាចឃាត់ខ្លួនជនល្មើស និងវត្ថុតាងជាក់ស្តែង រួចបញ្ជូនជនល្មើសព្រម ទាំងវត្ថុតាងទៅគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ឬសង្កាត់រដ្ឋបាលព្រៃឈើជុំគីរីពីបទល្មើសព្រៃឈើដែលបានជួបប្រទះក្នុងដែនព្រៃសហគមន៍របស់ខ្លួនដើម្បីចាត់វិធានការតាមនីតិវិធី។ សមាជិកសហគមន៍ព្រៃឈើណា មានស្នាដៃក្នុងការចូលរួមផ្តល់ព័ត៌មាន និងបង្ក្រាបបទល្មើសព្រៃឈើក្នុងព្រៃសហគមន៍ អាចទទួលបានរង្វាន់លើកទឹក ចិត្តស្របតាមមាត្រា៩២នៃច្បាប់ស្តីពីព្រៃឈើ។

---

[42] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២០០៩, ប្រការ៤៦។

[43] លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន, ២០០៩, ប្រការ៤៩។

## ៣.៦. ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយនៃការគ្រប់គ្រង

ការអនុវត្តការងារក្នុងកិច្ចការពារព្រៃឈើសហគមន៍ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ មានចំណុចខ្លាំង និងចំណុចខ្សោយ រួមមានដូចខាងក្រោមះ

### ៣.៦.១. ចំណុចខ្លាំង

- សហគមន៍ព្រៃឈើបានរៀបចំឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់
- សហគមន៍ព្រៃឈើមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងច្បាស់លាស់
- សហគមន៍ព្រៃឈើមានផែនការគ្រប់គ្រងព្រៃសហគមន៍ច្បាស់លាស់
- សហគមន៍ព្រៃឈើមានផែនការប្រជុំគណៈកម្មការគ្រប់គ្រងសមាជិកសហគមន៍តាមកាល
- មានការរៀបចំបញ្ជីសារពើភ័ណ្ឌព្រៃឈើសហគមន៍បានត្រឹមត្រូវល្អ
- មានការចូលរួមពីសមាជិកសហគមន៍ក្នុងទប់ស្កាត់បទល្មើសព្រៃឈើសហគមន៍
- ថតរូបធ្វើជាភស្តុតាង និងសរសេរកិច្ចសន្យាដោយនៅក្នុងកិច្ចសន្យាផ្តោតលើការដាក់ពិន័យ ឬការចាត់វិធានការដោយនាំយកទាំងសម្ភារៈ និងជនល្មើសទៅថ្នាក់ឃុំ និងសង្កាត់រដ្ឋបាលព្រៃឈើ
- យកច្បាប់ស្តីពីព្រៃឈើ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងវិស័យព្រៃឈើ ទៅផ្សព្វផ្សាយ និងបង្ហាញឱ្យគេដឹង
- មានវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការទប់ស្កាត់ព្រៃឈើតូចតាច មានក្រុមយាមល្បាតដេកនៅក្នុងព្រៃ
- មានឆន្ទៈបង់វិភាគទាន និងចំណាយទាំងកម្លាំងកាយចិត្ត ទាំងពេលវេលា ១ខែ ចំនួន ២០០រៀលក្នុងសមាជិកម្នាក់ៗ
- ចេះទំនាក់ទំនងជាមួយអ្នកមកពីខាងក្រៅសហគមន៍
- មានការចូលរួមពីប្រជាពលរដ្ឋក្នុងកិច្ចការពារព្រៃសហគមន៍

### ៣.៦.២. ចំណុចខ្សោយ

- ខ្វះខាតថវិកាទ្រទ្រង់សហគមន៍
- ខ្វះការយល់ដឹង/ចំណេះដឹងមិនទាន់បានទូលំទូលាយ
- ការចូលរួមពីអ្នកដឹកនាំ អាជ្ញាធរ/ស្ថាប័ន ពាក់ព័ន្ធមិនទាន់បានល្អប្រសើរ
- ខ្វះធនធានមនុស្ស (អ្នកចេះដឹង) ត្រូវបានគេអូសទាញជឿតាមគេ
- ខ្វះខាតសម្ភារៈល្បាតព្រៃ
- កិច្ចអន្តរាគមន៍ពីអាជ្ញាធរ/ស្ថាប័នពាក់ព័ន្ធមួយចំនួនពេលខ្លះមិនទាន់ពេលវេលា
- ខ្វះការលើកទឹកចិត្តដល់សមាជិកសហគមន៍ដែលមានថ្វីដៃក្នុងកិច្ចការពារព្រៃសហគមន៍

- ខ្វះមធ្យោបាយសម្រាប់បម្រើការងាសហគមន៍
- ខ្វះការគាំទ្រពីពីអង្គការដៃគូ
- ខ្វះសាមគ្គីភាព

យោងតាមការសិក្សាមួយផ្សេងទៀតស្តីពីសហគមន៍ព្រៃឈើ នៅក្នុងប្រទេសមួយចំនួនប្រចាំតំបន់អាស៊ីអាគ្នេយ៍បានរកឃើញថាសហគមន៍ព្រៃឈើ មានសក្តានុពលក្នុងការដើរតួនាទីដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែដើម្បីឱ្យមានប្រសិទ្ធិភាពត្រូវ[44]៖

- ត្រួតពិនិត្យគ្រប់គ្រងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ និងអំពើពុករលួយក្នុងវិស័យព្រៃឈើ
- ផ្លាស់ប្តូរតំបន់សហគមន៍ព្រៃឈើ ទៅកាន់កន្លែងណាដែលមានព្រៃឈើច្រើនហូរហៀរ
- ត្រូវបង្កើនប្រាក់ចំណូលដែលបានមកពីព្រៃឈើ តាមរយៈការទទួលបានសិទ្ធិពេញលេញ ការកាន់កាប់ និងការបែងចែកផលប្រយោជន៍ និងការលប់ចោលបទប្បញ្ញត្តិប្រឆាំងនឹងជនក្រីក្រ។

[44] William D. Sunderlin, *គោលនយោបាយ និងសេដ្ឋកិច្ចព្រៃឈើ*, Volum 8, Issue 4, មិថុនា ២០០៦, ៣៨៦-៣៩៦។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ យ៉ាងយកចិត្តទុកដាក់លើការរំលឹកទ្រឹស្តី ជាពិសេសតាមរយៈការចុះស្រាវជ្រាវ និងការអនុវត្តការងារជាក់ស្តែងរបស់សហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន ដែលពាក់ព័ន្ធនឹងប្រធានបទ **"ដំណើរការនៃគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន"** ដែលបានផ្តោតទៅលើដែនកំណត់មួយចំនួន ដូចជារបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរបស់សហគមន៍ព្រៃឈើ ដំណាក់អ្នកតាថ្មពូន ការកំណត់របៀបរបបការងាររបស់ប្រធានសហគមន៍ សហមាជិក គណៈកម្មការគ្រប់គ្រង និងសមាជិកសហគមន៍ ភារកិច្ចរបស់គណៈកម្មការ គ្រប់គ្រងសហគមន៍ព្រៃឈើ មុខងារប្រតិបត្តិការរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ផែនការអភិវឌ្ឍន៍ និងតម្រូវការរបស់សមាជិកសហគមន៍ ការបណ្តុះបណ្តាលសមាជិកសហគមន៍ ដែលនាំឱ្យយើងដឹងថា ដំណើរការនៃការអនុវត្តការងារសហគមន៍ព្រៃឈើ ដំណាក់អ្នកតាថ្មពូនប្រព្រឹត្តទៅតាមផែនការ និងសកម្មភាពដែលបានគ្រោងទុក ហើយទទួលបាននូវលទ្ធផលសមទៅតាមការរំពឹងទុក។

ការសិក្សាស្រាវជ្រាវលើប្រធានបទ ការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូននេះ បានបង្ហាញឱ្យដឹងថា មានសក្តានុពលជាច្រើនក្នុងការឱ្យសហគមន៍មូលដ្ឋានចូលរួមក្នុងការពារតំបន់ព្រៃឈើហួសពីព្រំដែនធម្មតានៃសហគមន៍ព្រៃឈើផ្លូវការ ដូចអនុវត្តនាពេលបច្ចុប្បន្ននៅកម្ពុជា។ សហគមន៍អាចមានសមត្ថភាពក្នុងការត្រួតពិនិត្យតាមដាន ការរាយការណ៍ និងការបង្ក្រាបបទល្មើសព្រៃឈើ នៅទីណាដែលបទល្មើសទាំងនោះកើតឡើង។ ប៉ុន្តែកិច្ចខិតខំប្រឹងទាំងនោះត្រូវការការទទួលស្គាល់ និងគាំទ្រពីអាជ្ញាធរពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលដើម្បីឱ្យមានប្រសិទ្ធភាព។ ម្ចាស់ជំនួយ និងអង្គការមិនមែនរាជរដ្ឋាភិបាលក៏អាចគាំទ្រចំពោះកិច្ចប្រឹងប្រែងទាំងនេះដោយការផ្តល់ជំនួយបច្ចេកទេស និងការអភិវឌ្ឍសហគមន៍ផងដែរ។ ក្នុងនោះផងដែរការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន បានឆ្លុះបញ្ចាំងការចូលរួមទប់ស្កាត់ និងកាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើនៅក្នុងតំបន់សហគមន៍ ជាមួយគ្នានោះដែរគឺដើម្បីរួមចំណែកដល់ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើរយៈពេលវែង ព្រមទាំងលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

# អនុសាសន៍

ទន្ទឹមនឹងការអនុវត្តការងារបានល្អប្រសើរ និងមួយចំនួននៅមានលក្ខណៈមិនទាន់ល្អប្រសើរ អ្នកសិក្សាសូមផ្តល់អនុសាសន៍មួយ ដើម្បីអោយសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូនមានដំណើរការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍ព្រៃឈើអោយកាន់តែមានប្រសិទ្ធភាពខ្ពស់ ដូចខាងក្រោមនេះ៖

– ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ គួរជួយគាំទ្រថវិកាប្រចាំឆ្នាំ ដើម្បីទ្រទ្រង់សហគមន៍ព្រៃឈើ ឱ្យមានដំណើរការល្អក្នុងកិច្ចការពារព្រៃសហគមន៍ឱ្យមានប្រសិទ្ធភាពខ្ពស់
– គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ គួរផ្តល់វគ្គបណ្តុះបណ្តាលដល់សមាជិកសហគមន៍ ឱ្យបានទូលំទូលាយលើជំនាញដែលពាក់ព័ន្ធទៅនឹងវិស័យព្រៃឈើ
– អ្នកភូមិទាំងអស់ដែលរស់នៅក្នុងមូលដ្ឋាន គួរលើកទឹកចិត្តឱ្យធ្វើការតាមដាន រាយការណ៍ និងសហការក្នុងការបង្ក្រាបបទល្មើសព្រៃឈើ នៅទីដែលបទល្មើសទាំងនេះកើតឡើង។ បើតំបន់ព្រៃសហគមន៍ មិនត្រូវបានពង្រីកធំដុំទេ ការផ្តោតដ៏តូចចង្អៀតលើការការពារព្រៃឈើសហគមន៍ ដែលត្រូវបានកំណត់ជាផ្លូវការតែម្យ៉ាង មិនអាចមានប្រសិទ្ធភាពក្នុងការពារធនធានព្រៃឈើទូទៅបានឡើយ
– តំបន់ព្រៃដែលបច្ចុប្បន្នមិនស្ថិតនៅក្រោមការគ្រប់គ្រងណាមួយ ដោយរាប់បញ្ចូលទាំងអតីតតំបន់ព្រៃសម្បទាននិងតំបន់ព្រៃសម្បទានដែលមិនដំណើរការ គួរពិចារណាសម្រាប់ការពារដោយសហគមន៍
– អង្គការមិនមែនរាជរដ្ឋាភិបាល អាចជួយសហគមន៍ក្នុងការពារតំបន់ព្រៃធំជាងនេះ ដោយការជួយសម្រួលរៀបចំសហគមន៍ ការផ្តល់ឧបករណ៍ បរិក្ខារ និងមូលនិធិចាំបាច់សម្រាប់ការបង្កើនកិច្ចប្រឹងប្រែងក្នុងការយាមល្បាតនិងការរាយការណ៍ពីបទល្មើសព្រៃឈើ
– សហគមន៍ព្រៃឈើ គួរត្រូវបានណែនាំឱ្យមានការប្រុងប្រយ័ត្ន នៅពេលពិចារណា ចាប់ខ្លួនជនល្មើស ឬរឹបអូសឧបករណ៍កាប់ឈើខុសច្បាប់ ជាពិសេសនៅពេលចុះល្បាតព្រៃនៅក្រៅព្រៃសហគមន៍ដែលបានកំណត់
– មន្ត្រីមូលដ្ឋានរបស់រដ្ឋបាលព្រៃឈើ ត្រូវការគោលការណ៍ណែនាំច្បាស់ និងបណ្តុះបណ្តាលពីរបៀបចាត់វិធានការបន្ទាន់នៅពេលសហគមន៍ រាយការណ៍ជូនពួកគេអំពីសកម្មភាពសច្បាប់ ដើម្បីសម្រេចបាននូវសេក្តានុពលពេញលេញសម្រាប់កិច្ចសហការជាមួយសហគមន៍ព្រៃឈើ
– ម្ចាស់ជំនួយគួរផ្តល់ជំនួយបច្ចេកទេស ដើម្បីជួយរាជរដ្ឋាភិបាលក្នុងការសម្រេចសក្តានុពលនៃកិច្ចសហការជាមួយសហគមន៍ព្រៃឈើ ជាពិសេសជួយធ្វើការបំភ្លឺអំពីសិទ្ធិរបស់សហគមន៍ព្រៃឈើក្នុងការជួយសម្រួលដល់ការបង្ក្រាបបទល្មើស

# គន្ថនិទ្ទេស

**ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

១. គោលការណ៍ណែនាំសហគមន៍ព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០០

២. ច្បាប់ស្តីពីព្រៃឈើ លេខ នស/រកម/០៨០២/០១៦ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២

៣. របាយការណ៍សារពើភ័ណ្ឌព្រៃឈើសហគមន៍ដំណាក់អ្នកតាថ្មពួន របស់ក្រុមការងារនៃគម្រោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើនៅកម្ពុជានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២

៤. អនុក្រឹត្យស្តីពីកាគ្រប់គ្រងសហគមន៍ព្រៃឈើ. លេខ៧៩ អនក្រ.បក ឆ្នាំ២០០៣

៥. បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួន ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣

៦. ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ២១៩ប្រក.កសក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦

៧. ដីកាស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួនឃុំស្រែក្នុង លេខ៨៩/០៩ ដ.ក ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩

៨. លក្ខន្តិកៈសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពួន ឆ្នាំ២០០៩

**សៀវភៅ**

១. ក្រសួងផែនការ៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ភ្នំពេញ ឆ្នាំ២០១០

២. ក្រសួងមុខងារសាធារណៈ៖ ការកែលំអការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ភ្នំពេញ ឆ្នាំ២០១៤

៣. ជា ចំរើន៖ មូលដ្ឋានគ្រឹះនៃភាពជាអ្នកដឹកនាំ ភ្នំពេញ ឆ្នាំ២០១២

៤. អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖ ជំនាញនៃការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់អ្នកគ្រប់គ្រងជាន់ខ្ពស់ ភ្នំពេញ ឆ្នាំ២០១០

៥. Douglas McGregor. The Human Side of Enterprise. UK: Cambridge University, 2006

៦. Fred R. David, Forest R. David. Strategic Management 15th Edition. USA: Courier Kendallville, 2015

# ឧបសម្ព័ន្ធ

## តារាងប្រភេទឈើក្នុងភូមិនីមួយៗ

(ការធ្វើសារពើភ័ណ្ឌព្រៃឈើក្នុងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន)

| ល.រ | ឈ្មោះឈើ | ភូមិព្រៃយ៉ាវ១៣ឡូត៍ | | ភូមិនត្បែងពក១២ឡូត៍ | | ភូមិដំណាក់ឈ្មួល ១២ ឡូត៍ | | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | ចំ.ដើម D>5 | ចំ.ដើម D<5 | ចំ.ដើម D>5 | ចំ.ដើម D<5 | ចំ.ដើម D>5 | ចំ.ដើម D<5 | | |
| ១ | ល្វៃ | ១ | ០ | ៣ | ៣ | ០ | ០ | ៧ | ០.២៩% |
| ២ | បាក់ដង | ១ | ០ | ០ | ១ | ២ | ០ | ៤ | ០.១៧% |
| ៣ | បាក់ដោក | ៣ | ០ | ០ | ០ | ០ | ០ | ៣ | ០.១២% |
| ៤ | ពពូលថ្ម | ១០ | ៤ | ១ | ០ | ០ | ០ | ១៥ | ០.៦៣% |
| ៥ | ពពេល | ៩ | ៦ | ០ | ១ | ០ | ០ | ១៦ | ០.៦៧% |
| ៦ | ពងមាន់ | ៣ | ១ | ៤ | ៤ | ០ | ៥ | ១៧ | ០.៧១% |
| ៧ | ពង្រ | ២ | ១ | ២ | ០ | ០ | ២ | ៧ | ០.២៩% |
| ៨ | ចង្អូត្នាត | ២ | ៣ | ២ | ០ | ០ | ២ | ៧ | ០.២៩% |
| ៩ | ពោនស្វា | ៦ | ១ | ៩ | ០ | ១ | ០ | ១៧ | ០.៧១% |
| ១០ | ជើងគោ | ១ | ០ | ០ | ០ | ០ | ០ | ១ | ០.០៤% |
| ១១ | ធ្មេញត្រី | ១ | ០ | ០ | ០ | ០ | ០ | ១ | ០.០៤% |
| ១២ | ហៃសាន | ១ | ០ | ៧ | ១ | ០ | ០ | ៩ | ០.៣៨% |
| ១៣ | ល្បៀក | ៤ | ០ | ២ | ០ | ៧ | ១ | ១៤ | ០.៥៩% |
| ១៤ | ឈើព្រីស | ១ | ០ | ០ | ០ | ០ | ០ | ១ | ០.០៤% |
| ១៥ | ច្រេស | ១ | ០ | ១ | ០ | ០ | ០ | ២ | ០.០៨% |
| ១៦ | គ្រើល | ១១ | ២ | ៧ | ៤ | ១ | ០ | ២៥ | ១.០៥% |
| ១៧ | ត្បែង | ៣១ | ៤ | ៩ | ០ | ០ | ០ | ៤៤ | ១.៨៥% |
| ១៨ | ថ្លាត់ | ៣ | ៣ | ៣ | ១ | ០ | ១ | ១១ | ០.៤៦% |
| ១៩ | ធ្លក | ១ | ០ | ០ | ០ | ២ | ០ | ៣ | ០.១២% |
| ២០ | ធ្លកឈ្មោល | ៥០ | ៨ | ២ | ៣ | ០ | ៣ | ៦៦ | ២.៧៧% |
| ២១ | អំបែងខ្មែរ | ១ | ០ | ១០ | ០ | ៤ | ៣ | ១៨ | ១.៧៦% |
| ២២ | ញព្រៃ | ១ | ១ | ១ | ០ | ១ | ២ | ៦ | ០.២៥% |
| ២៣ | កកោះ | ៦ | ២ | ១ | ០ | ០ | ០ | ៩ | ០.៣៨% |
| ២៤ | កណ្ដោល | ៥ | ០ | ៤ | ១ | ៣ | ០ | ១៣ | ០.៥៥% |
| ២៥ | ផ្ចឹក | ២១៧ | ៤៨ | ១៤០ | ៥៤ | ១០៧ | ៥១ | ៦១៧ | ២៥.៩២% |
| ២៦ | គ្រង់ | ១៩ | ៤ | ៤១ | ៩ | ៧ | ១៣ | ៩៣ | ៣.៩១% |
| ២៧ | រមាំង | ៤ | ៣ | ២ | ១១ | ១ | ៤ | ២៥ | ១.០៥% |
| ២៨ | ស្រម៉ | ២ | ០ | ៥ | ០ | ១ | ២ | ១០ | ០.៤២% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២៩ | សុក្រម | ៧៧ | ៧៧ | ១០៦ | ៩៩ | ១២៨ | ៨០ | ៥៦៨ | ២៣.៨៧% |
| ៣០ | ស្វាយព្រៃ | ៦ | ១ | ២ | ១ | ៣ | 0 | ១៣ | 0.៥៥% |
| ៣១ | ខ្ទុំ | ៤ | ១ | ៣ | 0 | 0 | 0 | ៨ | 0.៣៤% |
| ៣២ | ឃ្មុត | ១ | 0 | 0 | 0 | 0 | 0 | ១ | 0.0៤% |
| ៣៣ | ខ្លុង | ១៥៩ | ៣៩ | ១២១ | ៤៦ | ១១២ | ៣៣ | ៥១០ | ២១.៤៣% |
| ៣៤ | ពពូល | 0 | 0 | 0 | 0 | ១ | 0 | ១ | 0.0៤% |
| ៣៥ | ពន្ធំតាឡី | 0 | 0 | 0 | ១ | ១ | 0 | ២ | 0.0៨% |
| ៣៦ | ជ័យដំរី | 0 | 0 | ១៥ | ៣ | ១៥ | ៧ | ៤0 | ១.៧0% |
| ៣៧ | ទ្បើរអាវ | 0 | 0 | ២ | 0 | ១ | ៤ | ៧ | 0.២៩% |
| ៣៨ | ភ្លៅមាន់ | 0 | 0 | 0 | 0 | ១ | 0 | ១ | 0.0៤% |
| ៣៩ | ម្កាក់ព្រៃ | 0 | 0 | 0 | 0 | ១ | 0 | ១ | 0.0៤% |
| ៤០ | ឈ្លើក | 0 | 0 | ៤ | 0 | ១៦ | ៤ | ២៤ | ១.0១% |
| ៤១ | រាំង | 0 | 0 | ៣២ | ៣0 | ៦ | ១ | ៦៩ | ២.៩0% |
| ៤២ | ព្រីង | 0 | 0 | ១ | 0 | ១ | ៣ | ៥ | 0.២១% |
| ៤៣ | ព្រីងចន្លុះ | 0 | 0 | ១ | 0 | ២ | 0 | ៣ | 0.១២% |
| ៤៤ | រការ | 0 | 0 | 0 | 0 | ១ | 0 | ១ | 0.0៤% |
| ៤៥ | ស្រងាំ | 0 | 0 | ១ | ២ | ១ | ៥ | ៩ | 0.៣៨% |
| ៤៦ | ចង្កេះអង្រ្គង | 0 | 0 | ៦ | 0 | 0 | 0 | ៦ | 0.២៥% |
| ៤៧ | ចំបក់ | 0 | 0 | ៣ | ១ | 0 | 0 | ៤ | 0.១៧% |
| ៤៨ | ដង្កៀបក្ដាម | 0 | 0 | ២ | ៣ | 0 | 0 | ៥ | 0.២១% |
| ៤៩ | ល្បៀង | 0 | 0 | ៤ | 0 | 0 | 0 | ៤ | 0.១៧% |
| ៥០ | ឈើឃ្យូស | 0 | 0 | ១ | 0 | 0 | 0 | ១ | 0.0៤% |
| ៥១ | ធ្នង់ | 0 | 0 | ១ | ១ | 0 | ២ | ៤ | 0.១៧% |
| ៥២ | អំភោគ | 0 | 0 | ១0 | 0 | 0 | 0 | ១0 | 0.៤២% |
| ៥៣ | ខ្វាវ | 0 | ១ | ១ | 0 | ១ | ២ | ៥ | 0.២១% |
| ៥៤ | ភ្លូធំ | 0 | 0 | ២ | 0 | 0 | 0 | ២ | 0.0៨% |
| ៥៥ | រលួស | 0 | 0 | ១ | 0 | 0 | 0 | ១ | 0.0៤% |
| ៥៦ | ត្រយឹង | 0 | 0 | ១ | ២ | 0 | 0 | ៣ | 0.១២% |
| ៥៧ | សន្ទះខ្យង | 0 | 0 | ១ | 0 | 0 | 0 | ១ | 0.0៤% |
| ៥៨ | ទំពូង | 0 | 0 | ១ | ២ | 0 | 0 | ៣ | 0.១២% |
| ៥៩ | កន្ទួតព្រៃ | 0 | ៥ | 0 | 0 | 0 | 0 | ៥ | 0.២១% |
| ៦០ | ឃ្នាស | 0 | 0 | 0 | ៣ | 0 | 0 | ៣ | 0.១២% |